ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# បទដ្ឋានអនុវត្តបច្ចេកវិទ្យា

# ការចិញ្ចឹម គ្រប់គ្រងមេ និងកូនមាន់នៅជនបទ




រៀបចំដោយ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

សហការជាមួយ នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល



ឧបត្ថម្ភដោយ គំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី

**រៀបរៀងដោយ : បណ្ឌិត ខៀវ បូរិន**

**មជ្ឈមណ្ឌលអភិវឌ្ឍន៍ការចិញ្ចឹមសត្វ និងកសិកម្ម "សែលអាគ្រីត"**

ទូរស័ព្ទ : ០២៣ ២២៣៦៤០

អ៊ីម៉ែល : celagrid@celagrid.org

**កាលបរិច្ឆេទ : ខែ កក្កដា ឆ្នាំ ២០០៦**

© រក្សាសិទ្ធិគ្រប់យ៉ាង : គ្រប់បទដ្ឋានអនុវត្តបច្ចេកវិទ្យា (បអប) ទាំងអស់រួមទាំងឯកសារនេះ ជាកម្មសិទ្ធិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយសំរេចផ្តល់អោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ធ្វើជាម្ចាស់កម្មសិទ្ធិ ។ រាល់សំណើសុំផលិតបន្ថែម ត្រូវសុំការអនុញ្ញាតសិទ្ធិជាមុន ពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

# បុព្វកថា

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រោមកិច្ចសហការគាំទ្រពីទីភ្នាក់ងារអូស្ត្រាលីសំរាប់ការអភិវឌ្ឍន៍អន្តរជាតិ (AusAID) តាមរយៈគំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី ជំហានទី២ (២០០១-២០០៦) ដែលមានគោលដៅពង្រឹងស្ថាប័ន និងប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅកម្ពុជា បានខិតខំយ៉ាងពេញទំហឹងដើម្បីធ្វើការពង្រឹងសមត្ថភាពមន្ត្រីផ្សព្វផ្សាយកសិកម្ម ការរៀបចំកសាងផែនការផ្សព្វផ្សាយកសិកម្មស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល តាមរយៈការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានថ្នាក់ឃុំសង្កាត់ និងបានចងក្រងជាបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះឡើង។

បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ បានចងក្រងដោយអ្នកជំនាញឯកទេស (Subject Matter Specialist) នឹងត្រូវបានឆ្លងការពិនិត្យពិគ្រោះយោបល់ និងឯកភាពយល់ព្រមពីគណៈកម្មការបច្ចេកទេសដែលមានសមាសភាពមកពីនាយកដ្ឋានជំនាញនានា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងអ្នកពាក់ពន្ធ័ផ្សេងៗទៀត។ ឯកសារដ៏មានសារៈសំខាន់នេះ គឺជាឯកសារគោលដែលពិពណ៌នាអំពី ព័ត៌មាន បច្ចេកទេស វិធីសាស្ត្រ នីតិវិធី និងផែនការថវិកាចំណាយសម្រាប់ជួយដល់ មន្ត្រីកសិកម្មស្រុក និងភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាននានាយកទៅប្រើប្រាស់ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក្នុងបំណងផ្ទេរចំណេះដឹង ព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មតាមគ្រប់រូបភាពឱ្យបានជ្រួតជ្រាបដល់ប្រជាកសិករ និង ផលិតករដែលរស់នៅក្នុងតំបន់មានសក្តានុពលភាពស្របតាមលក្ខខ័ណ្ឌភូមិសាស្ត្រ សេដ្ឋកិច្ចសង្គម និងតម្រូវការចាំបាច់ជាក់លាក់នៅមូលដ្ឋាន ។

ដូច្នេះបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ មានសារៈប្រយោជន៏ជារួមសម្រាប់មន្ត្រីកសិកម្មខេត្ត-ក្រុង យកទៅប្រើប្រាស់ក្នុងការចូលរួមដោះស្រាយបញ្ហាចំពោះមុខ ដែលប្រជាកសិករយើងកំពុងប្រឈមមុខនៅក្នុងការធ្វើផលិតកម្មកសិកម្ម ពិពិធកម្មកសិកម្ម ដើម្បីធានាសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលគ្រួសារ ជាពិសេសរួមចំណែកកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គាំទ្រនូវឯកសារបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ ដែលជាឯកសារគោលសម្រាប់មន្ត្រីកសិកម្មស្រុក ខេត្ត-ក្រុង អង្គការក្រៅរដ្ឋាភិបាល ភ្នាក់ងារប្រតិបត្តិនានានៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់ យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យាដល់ប្រជាកសិករនៅជនបទឱ្យទូលំទូលាយ និងទទួលបានផ្លែផ្កាល្អប្រសើរប្រកបដោយក្តីសង្ឃឹម។

**រដ្ឋមន្ត្រី**

# អារម្ភកថា

ពាក្យពេញនៃ **បអប** គឺ"បទដ្ឋានអនុវត្តបច្ចេកវិទ្យា" ។ បអប ពន្យល់ពីរបៀបអនុវត្តបច្ចេកវិទ្យាដើម្បីជួយដោះស្រាយបញ្ហាផ្នែកកសិកម្មរបស់កសិករ ។ បអប ផ្ទុកនូវព័ត៌មានបទដ្ឋាន និងសំភារៈសម្រាប់ឱ្យមន្ត្រីផ្សព្វផ្សាយផ្ទេរបច្ចេកវិទ្យានេះទៅកសិករ ។ គោលគំនិតនៃបអប គឺដើម្បីផ្សព្វផ្សាយដល់ឃុំ ស្រុក និងខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។ បអប ត្រូវបានគេសរសេរសម្រាប់អោយមន្ត្រីផ្សព្វផ្សាយ អង្គការក្រៅរដ្ឋាភិបាល និងផ្នែកផ្សេងៗទៀតដែលបំរើការនៅក្នុងវិស័យអភិវឌ្ឍន៍ កសិកម្មនៅតាមមូលដ្ឋានប្រើប្រាស់។ បអប មានលក្ខណៈដូចខាងក្រោមនេះ :-

- អាចបត់បែនបាន-បអប អាចយកទៅអនុវត្តបាននៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា
- សាមញ្ញ-បអប អាចប្រើប្រាស់បានដោយគ្រប់ផ្នែកដែលបំរើការនៅតាមមូលដ្ឋាន
- ងាយយល់-ងាយស្រួលក្នុងការផ្តល់នូវព័ត៌មានសំខាន់ៗ

បអប ត្រូវបានកំណត់អាទិភាពដោយផ្អែកទៅតាមបញ្ហាផ្នែកកសិកម្មសំខាន់ៗរបស់កសិករតាមរយៈប្រភពជាច្រើនដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (FSMIS) ដែលផ្ទុកនូវព័ត៌មានសំខាន់ៗរបស់កសិករ ។ បញ្ហាផ្នែកកសិកម្មរបស់កសិករ ត្រូវបានគេវិភាគតាមរយៈការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានថ្នាក់ឃុំ (AEA) នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។បអប មាននៅតាមស្ថាប័ននានាដូចខាងក្រោម:

- វិទ្យាស្ថានស្រាវជ្រាវជាតិ
- ក្រុមកសិករ
- អង្គការក្រៅរដ្ឋាភិបាល
- ទីភ្នាក់ងារស្រាវជ្រាវអន្តរជាតិ
- កម្មវិធីផ្សព្វផ្សាយ
- ម្ចាស់ជំនួយ
- ផ្នែកឯកជន

បអប ត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ បអប ត្រូវបានសរសេរដោយអ្នកឯកទេសដែលមានបទពិសោធន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះ បអប ផ្ទុកនូវបទពិសោធន៍ល្អៗសម្រាប់អនុវត្តបច្ចេកវិទ្យា។ បអប ត្រូវបានឆ្លងកាត់ការត្រួតពិនិត្យរបស់ក្រុមការងារ បអប បន្ទាប់មកអនុម័តនិងអនុញ្ញាតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់ប្រើប្រាស់នៅតាមមូលដ្ឋាន ។

# ការចិញ្ចឹម គ្រប់គ្រងមេ និងកូនមាន់នៅជនបទ

ទំព័រ


**១. សេចក្តីអធិប្បាយ ........................................................ ១**

**២. ការណែនាំបច្ចេកទេស ................................................... ៤**

**២.១ ហេតុផលនៃការបង្កើត ‘TIP’ នេះ .......................................... ៤**

**២.២ ការកែលំអលើការគ្រប់គ្រង ................................................ ៥**

២.២.១ ក្រុងមេមាន់ក្នុងទ្រុង ........................................................ ៦

២.២.២ ការសង់ទ្រុង ឬអង្រុតដាក់មាន់ ............................................. ៧

២.២.៣ ការគ្រប់គ្រងមាន់ និងទ្រុង .................................................. ៩

២.២.៤ បង្កើនផលិតភាពមេមាន់ ................................................... ១០

**២.៣ ការកែលំអចំណី និងការផ្តល់ចំណី ......................................... ១២**

២.៣.១ ចំណីមានដើមកំណើតពីសត្វ ................................................ ១២

២.៣.២ គ្រាប់ធញ្ញជាតិ .............................................................. ១៦

២.៣.៣ វារីរុក្ខជាតិ និងស្លឹករុក្ខជាតិផ្សេងទៀត ....................................... ១៧

២.៣.៤ សង្ខេបជម្រើសសម្រាប់លាយចំណី ........................................... ២៥

**២.៤ ការចាក់ថ្នាំការពារ និងផ្សេងៗ ............................................... ២៧**

**២.៥ ផលចំណេញផ្នែកសេដ្ឋកិច្ច ..................................................... ២៩**

**២.៦ ផលប៉ះពាល់លើបរិស្ថាន ....................................................... ៣២**

**៣. ការណែនាំលើការខាផ្សព្វផ្សាយ ............................................. ៣៣**

**៣.១ វិធីសាស្ត្រនៃការផ្សព្វផ្សាយ ...................................................... ៣៣**

**៣.២ ឱកាសសម្រាប់ការធ្វើបណ្តាញ.................................................... ៣៧**

**៣.៣ កន្លែងរកឯកសារបន្ថែម ......................................................... ៣៨**

**៣.៤ យោនឯរ ......................................................................... ៣៩**

## ១. សេចក្តីអធិប្បាយ

### សេចក្តីសង្ខេបៈ

**បញ្ហា** : កូនមាន់ដែលញាស់នៅរស់បានតិច

**គោលដៅ** : ដើម្បីផលិតកូនមាន់ ២០០ ក្នុងមួយឆ្នាំ ពីមេមាន់ ៥ និងជួយការពារពីឧបត្តិហេតុ ការវាយប្រហារពីសត្វធំៗ និងជម្ងឺ ។

**វិធីសាស្រ្ត** : ១- បង្ខាំងមេមាន់ និងកូនមាន់ នៅក្នុងទ្រុង ឬរបងបាំង

២- ផ្តល់ការយកចិត្តទុកដាក់លើសុខភាពមាន់

៣- រៀបចំចំណីអោយប្រសើរជាងមុន

៤- ការគ្រប់គ្រងមេមាន់ប្រសើរជាងមុន ដើម្បីផ្តល់កូនញាស់ច្រើនក្នុងមួយឆ្នាំៗ

### លក្ខណៈវិនិច្ឆ័យបច្ចេកទេសសមស្របៈ

ខាងក្រោមនេះ ជាលក្ខខ័ណ្ឌចាំបាច់សម្រាប់ការអនុវត្តន៍ ‘TIP’ នេះ ដើម្បីសំរេចជោគជ័យ លើទិសដៅលើកឡើងខាងលើ:

**យែនឌ័រ :**

- ស្ត្រីមានលក្ខណៈសមស្របសម្រាប់ជ្រើសរើសឱ្យចូលរួមក្នុងការអនុវត្តន៍បែបបទបច្ចេសទេសនេះ ដោយពួកគេជាអ្នកចាត់ចែង និងទទួលខុសត្រូវការងារនៅក្នុងផ្ទះស្ទើរទាំងអស់ ។ បែបបទបច្ចេសទេសនេះ អាចលើកស្ទួយស្ត្រីក្នុងការរកចំណូលបន្ថែមសម្រាប់ជួយជ្រោមជ្រែងដល់គ្រួសារ ជាពិសេសដល់ការធ្វើឱ្យប្រសើរឡើង ដល់អាហាររូបត្ថម្ភដល់កូនៗ និងប្រាក់សម្រាប់បង់ថ្លៃសាលា និងការចំណាយផ្សេងៗ ។

**អាកាសធាតុ/ទឹក :**

តម្រូវការទឹកមានតិចតួចបំផុតសម្រាប់អនុវត្ត ‘TIP’ នេះ ដូចជាទឹកសម្រាប់មាន់ផឹក តែប្រសិនណាកសិករត្រូវផលិតចំណីមួយចំនួនដូចជា ចកបាយទា និងត្រកួន ជាប្រូតេអ៊ីន សម្រាប់មាន់ ពួកគេត្រូវការទឹកសម្រាប់ស្រោចស្រព និងបន្ថែមក្នុងស្រះចកនៅរដូវប្រាំង ។

- មាន់ងាយទទួលអំពើ នៅពេលមានសីតុណ្ហភាពខ្ពស់ ឬទាប ។ ស៊ីតុណ្ហភាពសមស្របសម្រាប់មាន់នោះ គឺនៅរដូវភ្លៀង និងដើមរដូវប្រាំង ។ ដូច្នេះហើយ ដើម្បីបន្តចិញ្ចឹមមាន់ នៅរដូវប្រាំង អ្នកចិញ្ចឹមត្រូវរៀបចំទ្រុងមានម្លប់ជ្រកត្រឹមត្រូវ (ក្រោមម្លប់ដើមឈើ) ដើម្បីឱ្យសត្វជ្រកនៅពេលមានថ្ងៃក្តៅខ្លាំង ។ សម្រាប់កូនមាន់អាយុ ១-៧ថ្ងៃ ត្រូវផ្តល់កំដៅ ដល់កូនមាន់ជាពិសេសនៅរដូវ

វស្សា ឬដើមរដូវប្រាំង ។ មាន់ស្រុកអាចធំធាត់លឿន នៅពេលសីតុណ្ហភាពស្ថិតនៅក្រោម ៣០ អង្សារសេ ។

**ភូមិសាស្ត្រ :**

- 'TIP' នេះ អាចអនុវត្តនៅគ្រប់ទីកន្លែងទាំងអស់ នៃប្រទេសកម្ពុជា គ្រាន់តែពិចារណា ទៅលើធនធានចំណីអាហារដែលមាន ឬដែលត្រូវដាំស្របទៅតាម លក្ខខណ្ឌជាក់លាក់របស់តំបន់ភូមិសាស្ត្រនិមួយៗ ។ ផ្ទុយទៅវិញ សម្រាប់ភូមិដែលលិចទឹកនៅរដូវវស្សា អាចមានការលំបាកសម្រាប់ អនុវត្ត 'TIP' នេះ តែអាច រៀបចំបាននៅរដូវទឹកសំរក ។

**ទំហំទីកន្លែង :**

- ដើម្បីចិញ្ចឹមកូនមាន់ (១៥-២០ក្បាល) និងមេមាន់ មួយក្បាល ត្រូវការផ្ទៃដីទំហំ ១,៥ គុណ ១,៥ ម៉ែត្រ ។ ដូច្នេះដើម្បីចិញ្ចឹមមេមាន់ ៥ក្បាល កសិករ ត្រូវមាន ដីប្រមាណ ១៥-២០ម$^{២}$ ។ ដោយសារគោលបំណងនៃ 'TIP' នេះ គឺ បង្កើនកូនមាន់ឱ្យច្រើន និងមានសុខភាពល្អ សម្រាប់បំប៉នយកសាច់ ដូចនេះកសិករត្រូវមានដីប្រមាណ ២៥-៣០ម$^{២}$ ទៀត សម្រាប់បំប៉នមាន់ពី ៤៥ថ្ងៃ ទៅដល់ពេលលក់ ។

**តម្រូវការពលកម្ម :**

- មនុស្សម្នាក់នៅក្នុងគ្រួសារ ជាពិសេសស្ត្រីអាចចំណាយពេល ១ម៉ោង ក្នុងមួយថ្ងៃសម្រាប់ ដាក់ទឹក-ចំណី សំអាត និងការងារបន្ទាប់បន្សំតិចតួចទៀត អាចគ្រប់គ្រាន់សម្រាប់មេមាន់ ៥ក្បាល ។ ប៉ុន្តែដើម្បីប្រើប្រាស់ពលកម្មគ្រួសារឱ្យកាន់តែមានប្រសិទ្ធិភាព ហើយធ្វើឱ្យ 'TIP' នេះកាន់តែមានផលប្រយោជន៍នោះ គួរលើកទឹកចិត្តឱ្យគ្រួសារនិមួយៗ ចិញ្ចឹមពី ១០-១៥ មេមាន់ ។ អាចតម្រូវការពលកម្មច្រើន នៅពេលសាងសង់ទ្រុង ផលិតចំណី និងរៀបចំ រណ្តៅសម្រាប់ផលិតចកបាយទា ឬថ្នាលត្រកួន ។ល។ នៅពេលចាប់ផ្តើម ។

**ស្ថានភាពសេដ្ឋកិច្ចកសិករ :**

- ការចិញ្ចឹមមាន់ មានការចាប់អារម្មណ៍ពិសេស ដល់មនុស្សដែលមានមធ្យោបាយ និងធនធានតិចតួច ដោយសារត្រូវការចំណាយតិចសម្រាប់អនុវត្ត ។
- កសិករដែលមានថវិកា ១៥០.០០០-២០០.០០០ រៀល អាចយក 'TIP' នេះ ទៅអនុវត្តបាន ។

**អនុសាសន៍ផ្សេងទៀត :**

- កសិករត្រូវជ្រើសរើសពូជក្នុងស្រុកដែលមានសក្តានុពលសម្រាប់ការលូតលាស់ ។ ទោះបីកសិករមានចំណេះដឹង លើការជ្រើសរើសពូជមាន់ល្អក៏ដោយអ្នកផ្សព្វផ្សាយ និងអ្នកមានឯកទេស ចិញ្ចឹមមាន់អាចជួយជ្រោមជ្រែងការងារនេះ ។

---

## ២. ការណែនាំបច្ចេកទេស

### ២.១ ហេតុផលនៃការបង្កើត 'TIP' នេះ

មាន់អាចផ្តល់ប្រាក់ចំណូលល្អណាស់សម្រាប់កសិករនៅជនបទ ជាពិសេសកសិករក្រីក្រនៅតាមសហគមន៍ដែលមានធនធានស្តួចស្តើង ។ ផ្អែកទៅលើការសំភាសន៍កសិករនៅប្រទេសកម្ពុជា ពួកគាត់អាចរកចំណូលបានពីការលក់មាន់សម្រាប់ទិញសំភារៈស្ទើរតែទាំងអស់សម្រាប់កូនទៅសាលារៀន ។ នៅពេលជាមួយគ្នានេះដែរ មាន់អាចផ្តល់ជាអាហារប្រូតេអ៊ីនសម្រាប់គ្រួសារ និងពិធីបុណ្យទានផ្សេងៗ ។

ការចិញ្ចឹមមាន់មានប្រជាប្រិយភាពខ្ពស់ប្រៀបធៀបជាមួយសត្វដទៃទៀត ដោយសារការវិនិយោគទាប ។ ទន្ទឹមនេះ ការចិញ្ចឹមមាន់នៅជនបទជួបប្រទះបញ្ហា និងការខាតបង់ជាច្រើន ។ ជាទូទៅកសិករមិនដែលបានទទួលផលចំណេញទៅតាមអ្វីដែលគាត់ត្រូវទទួលបាននោះទេ ។ កត្តាដែលរាំងស្ទះដល់ផលិតកម្មមាន់មាន: ជម្ងឺ ចំណី និងការផ្តល់ចំណី និងការគ្រប់គ្រង ។ បទពិសោធន៍នៅស្រុកបាទី ខេត្តតាកែវ បានបង្ហាញថា នៅពេលដែលមាន់បានចាក់ថ្នាំការពារជម្ងឺសំខាន់ៗពីរ (ដង្កោរ និងអាសន្នរោគ) កសិករអាចទាញយកផលយ៉ាងហោចណាស់ ៦០-៧០ភាគរយ នៃចំនួនមាន់ចិញ្ចឹមសរុប ។

ប្រព័ន្ធចិញ្ចឹមមាន់បែបបុរាណ មិនសូវបានផ្តល់ចំណីបន្ថែមដល់មាន់ទេ ហើយប្រសិនបើមានផ្តល់ចំណីបន្ថែមវិញ គេច្រើនឱ្យស្រូវ ឬអង្ករដល់មាន់គ្រប់ប្រភេទស៊ី ។ ការផ្តល់ចំណីបន្ថែមឱ្យមាន់ដែលមានគុណភាពមិនល្អ មិនអាចទាញយកសក្តានុពលភាពនៃការលូតលាស់របស់មាន់ទេ ជាពិសេសសម្រាប់កូនមាន់ដែលតម្រូវផ្តល់ចំណី មានប្រូតេអ៊ីនខ្ពស់ទាំងគុណភាព និងបរិមាណ ។ ដូច្នេះជាការចាំបាច់ កសិករគួរផ្តល់ចំណី ឱ្យមានគុណភាពដល់កូនមាន់ពីអាយុ ១-៤៥ថ្ងៃ ។

មេមាន់ជាទូទៅត្រូវបានឱ្យបណ្តើរកូនរបស់វា ដោយមានការអន្តរាគមន៍តិចតួចពីម្ចាស់ ។ ការចិញ្ចឹមប្រភេទនេះ ធ្វើឱ្យកូនមាន់ងាយទទួលរងនៅគ្រោះថ្នាក់ផ្សេងៗដោយសារការយាយីពីសត្វផ្សេងៗដូចជាឆ្កែ ឆ្មារ ស្ការ ។ល។ ហេតុដូចនេះហើយ ការកែលំអលើការងារគ្រប់គ្រង និងការថែទាំនៅក្នុងដំណាក់កាលដែលកូនមាន់នៅមានអាយុតិចតួចនេះ ធានាឱ្យការរស់រានច្រើនរបស់កូនមាន់ និងឈានទៅដល់ការផលិតកូនមាន់មានសុខភាពល្អសម្រាប់ដំណាក់កាលបំប៉ន ។

តាមការសង្កេតមើលនៅតាមភូមិជនបទ មេមាន់ភាគច្រើនបណ្តើរកូនតែ ៤-៥ ក្បាលប៉ុណ្ណោះ ដែល ជាហេតុបណ្តាលឱ្យថយចុះផលិតភាពរបស់មេមាន់ ។ ផ្ទុយទៅវិញយើងអាចបង្កើនផលិតភាពមេមាន់បាន តាមរយៈការប្រមូលកូនមាន់ដែលកើតនៅថ្ងៃប្រហាក់ប្រហែលគ្នា (៣-៥ ថ្ងៃ) បញ្ចូលឱ្យស្ថិត

នៅក្រោម ការគ្រប់គ្រងរបស់មេមាន់មួយ ហើយមេមាន់ដែលកូនត្រូវបានយកឱ្យមេមួយទៀតបណ្តើរនោះ ត្រូវដាក់ ទ្រុងរយៈពេល៤-៥ថ្ងៃមុនលែងមេមាន់ឱ្យដើរជាមួយឈ្មោលវិញនោះ។អនុវត្តតាមវិធីនេះអាចធ្វើឱ្យមេមាន់ ដែលមិនបណ្តើរកូននេះអាចឆាប់ពងឡើងវិញ។ ដូច្នេះហើយជាការចាំបាច់ណាស់ត្រូវធ្វើបង្ហាញដល់កសិករ ដើម្បីឱ្យពួកគាត់យល់ដឹង ហើយអាចអោយពួកគាត់ទទួលបានចំណូលខ្ពស់ពីការចិញ្ចឹមមាន់នេះ ។

## ២.២ ការកែលំអការគ្រប់គ្រង

នៅក្នុងការចិញ្ចឹមមាន់តាមប្រព័ន្ធបុរាណ កូនមាន់ត្រូវបានឱ្យដើររកស៊ីជាមួយមេវា ដែលធ្វើឱ្យកូនមាន់ជួបប្រទះនឹងគ្រោះថ្នាក់ជាច្រើនរួមបញ្ចូលទាំង ឆ្កែ ឆ្មារ ស្ការ ។ល។ ដើម្បីកាត់បន្ថយបញ្ហានេះ ការកែលំអលើការគ្រប់គ្រង ត្រូវបានដាក់បញ្ចូលទៅក្នុងការចិញ្ចឹមមាន់នេះ ។ វិធានការមួយដើម្បីសំរេចបានគោលបំណងនេះ ភ្នាក់ងារផ្សព្វផ្សាយត្រូវធ្វើបង្ហាញដល់កសិករ ស្តីពីការចិញ្ចឹមមេមាន់ក្រុងក្នុងទ្រុង តែលែងកូនវាអាចដើរនៅទីមួយដែលបានបាំងរបងកំណត់ ។



ការគ្រប់គ្រងនៃការចិញ្ចឹមមាន់មេ ខ្នាតកណ្តាល-៥០ក្បាល



គ្រប់គ្រងការចិញ្ចឹមមាន់មេតាមគ្រួសារ ៥-១០ក្បាល

### ២.២.១ ក្រុងមេមាន់ក្នុងទ្រុង

កសិករមួយចំនួនរក្សាទុកមេមាន់ និងកូនវាក្នុងទ្រុងរយៈពេល៣-៥ថ្ងៃក្រោយពេលញាស់ តែមានភាគច្រើនលែងមេមាន់ និងកូនវាតាមលក្ខណៈធម្មជាតិ ។ នៅដំណាក់កាលដំបូងនៃជីវិតនៈ កូនមាន់ត្រូវការថែទាំចាំបាច់រួមបញ្ចូលទាំងការផ្តល់កំដៅពីមេរបស់វាផង។ ដូច្នេះហើយអ្នកចិញ្ចឹមមាន់គួរដាក់កូនមាន់ និងមេនៅក្នុងទ្រុងនៅដំណាក់កាលនេះ។ទោះបីកូនមាន់ត្រូវបានដាក់ទ្រុងជាមួយមេរបស់មេវាក៏ដោយ វាមានលទ្ធភាពអាចចេញក្រៅទ្រុងចេញពីមេវា ដើម្បីធ្វើចលនា តែមេវាមិនអាចចេញបានទេ ។ ទ្រុងក្រុងមេមាន់ត្រូវដាក់ផ្ទាល់ដី តែអាចរំកិលទៅកន្លែងផ្សេងបានប្រសិនចាំបាច់។នៅចុងរយៈពេល៤៥ថ្ងៃ កូនមាន់អាចមានទម្ងន់ ២០០-២៥០ក្រាម ក្នុងមាន់និមួយៗហើយកូនមាន់ទាំងនេះអាចយកទៅដាក់ទ្រុងថ្មី

សម្រាប់ បំប៉នយកសាច់ ។ មានជម្រើសមួយចំនួនដូចរៀបរាប់ខាងក្រោមនេះ ដែលភ្នាក់ងារផ្សព្វផ្សាយអាចជ្រើសរើសសម្រាប់ណែនាំដល់កសិករចិញ្ចឹមមាន់ ។

ក. នៅពេលដែលផ្ទះស្ថិតនៅជិតគ្នា ជាការចាំបាច់ត្រូវធ្វើរបងបិទបរិវេណ ៣ ម៉ែ ជុំវិញទ្រុងក្រុងមេមាន់ ដើម្បីឱ្យកូនមាន់មានទីកន្លែងធ្វើចលនានៅក្នុងទីតាំងមួយកំណត់ ជៀសវាងសត្វដទៃទៀតចាប់កូនមាន់ជាចំណី ។ការអនុវត្តន៍តាមវិធីនេះ កាត់បន្ថយការងាប់ដោយសារគ្រោះថ្នាក់ផ្សេងៗទៀតទៅលើកូនមាន់ ។

ខ. នៅពេលដែលផ្ទះមិនស្ថិតនៅជិតគ្នានោះទេ (ឧទាហរណ៍ ផ្ទះដែលសាងសង់នៅកណ្តាលវាលស្រែ) កសិករអាចប្រើជម្រើសទី ក. ឬមួយទុកមេមាន់ក្រុងនៅក្នុងទ្រុង ហើយឱ្យកូនវាអាចធ្វើចលនា និងដើររកចំណីនៅជុំវិញទីនោះ ។ ប៉ុន្តែបើអនុវត្តតាមជម្រើសដែលបានលើកឡើងនេះ កសិករនឹងធានាថា គ្មានសត្វកាចសាហាវដែលយាយីដល់កូនមាន់ ។




**ការកែលំអលើការគ្រប់គ្រងកូនមាន់**




**មេមាន់ក្រុងក្នុងទ្រុង**

**ចំណាំ:** កូនមាន់ជាធម្មតា មិនដើរឆ្ងាយពីមេរបស់វាទេ ដោយសារមេមាន់តែងតែស្រែកហៅកូនវាជាញឹកញាប់ ដើម្បីឱ្យចំណីស៊ី ឬក្នុងករណីមានអាសន្ន ។

## ២.២.២ ការសង់ទ្រុង ឬអង្រុតដាក់មាន់

○ សំភារៈសម្រាប់ធ្វើទ្រុង ឬអង្រុតក្រុង និងរបង

ក្រុង ឬអង្រុតក្រុងមេមាន់ អាចសាងសង់ដោយសំភារៈសាមញ្ញដែលមាននៅក្នុងភូមិ ដែលធ្វើឱ្យកសិករចំណាយប្រាក់កាស់តិចតួចទៅលើការសាងសង់ទ្រុង ឬអង្រុតក្រុង និងរបង:

- ឫស្សី
- កូនឈើ

- ស្លឹក និងធាងត្នោត
- សំណាញ់ ឬមង និងព្រួលដាក់ត្រីចាស់ៗ
- ដើមដំឡូងឈើសម្រាប់ធ្វើរបងបៃតង ប្រសិនបើមាន

○ ការធ្វើអង្រុតក្រុង

អង្រុតក្រុងត្រូវបានធ្វើឡើងដើម្បីក្រុងមេមាន់ ហើយទន្ទឹមគ្នានោះកូនវាត្រូវបានលែងឱ្យដើររកស៊ី នៅទីតាំងព័ទ្ធរបងមួយ ។ ទ្រុងក្រុងអាចសង់ជាទំរង់មូល ឬការ៉េ ។ តែកសិករអាចសាងសង់ទំរង់ផ្សេងទៀតក៏បាន អាស្រ័យទៅតាមបទពិសោធន៍ វត្ថុធាតុដើម និងចំណង់ចំណូលចិត្ត តែមាំសម្រាប់ដាក់សត្វ ។ ជាឧទាហរណ៍សម្រាប់កសិករយកទៅធ្វើអង្រុតក្រុងមេមាន់ មានដូចខាងក្រោម :

- កំពស់ ០,៤-០,៥ ម
- ផ្ទៃក្រឡា ០,៥ គុណ ០,៥ ម
- មានទ្វារបិទបើក ៤ ដែលមានទទឹងប្រមាណ ៥សម និងកំពស់ ៨សម ត្រូវបានចោះនៅជាប់ដី ដែលអាចឱ្យកូនមាន់ចេញពីមេ ធ្វើចលនានៅជុំវិញទីធ្លាកំណត់ ។

**ចំណាំ :**

- ទ្រុងក្រុងមេមាន់អាចលើកបាន ឬងាយស្រួលរំកិលទៅទីកន្លែងដទៃនៅក្នុងបរិវេណដែលបានធ្វើរបងដើម្បីធ្វើការសំអាត ។
- ទ្វារទាំង ៤ ងាយស្រួលបិទនៅពេលយប់ ហើយទាំងមេមាន់ និងកូនត្រូវរំកិល ឬដើរទៅកន្លែងមានសុវត្ថិភាព (ក្នុងករណីគ្មានដំបូលបាំងភ្លៀង ជាពិសេសនៅរដូវវស្សា) ។



**ទ្រុងក្រុងមេមាន់មានទំរង់មូលធ្វើពីឬស្សី**



**ទ្រុងក្រុងមេមាន់មានទំរង់បួនជ្រុងធ្វើឈើ និងឬស្សី**

## ២.២.៣ ការគ្រប់គ្រងមាន់ និងទ្រុង

ភ្នាក់ងារផ្សព្វផ្សាយណែនាំឱ្យកសិករសាងសង់ប្រព័ន្ធចិញ្ចឹមមាន់នេះនៅក្បែរផ្ទះ ដើម្បីសំរួលដល់ការអនុវត្តន៍ការងារ និងងាយស្រួលពិនិត្យមើលមាន់ផង ។ ប្រព័ន្ធនេះ ត្រូវរៀបចំនៅទីខ្ពស់ ដីទួលងាយស្រួលទឹកភ្លៀងហូរលឿន និងឆាប់ស្ងួតក្រោយភ្លៀងរួច ។ កត្តាសំខាន់ផ្សេងទៀត ត្រូវធ្វើទ្រុងនេះនៅក្រោមម្លប់ឈើ ឬមានដំបូល ។

នៅពេលយប់ ទ្វារតូចៗទាំង ៤ ត្រូវបានបិទ ហើយត្រូវរំកិល ឬចាប់មេមាន់ និងកូនទៅទីមានសុវត្ថិភាព ដើម្បីជៀសវាងការយាយីរបស់សត្វកាចសាហាវផ្សេងៗទៀត រួមបញ្ចូលឆ្កែ និងឆ្មាផងដែរ ហើយការពារមាន់ទាំងអស់កុំឱ្យទទឹកភ្លៀង (ខែឧសភា-តុលា) ។

ការចិញ្ចឹមមាន់ខ្នាតធំ ឬឧស្សាហកម្ម គេប្រើប្រាស់ភ្លើងអគ្គីសនីដើម្បីផ្តល់កំដៅដល់កូនមាន់ ក្រោយពេលញាស់ តែចំពោះការចិញ្ចឹមមាន់ខ្នាតតូច ឬជាលក្ខណៈគ្រួសារ ធ្យូងអាចយកទៅប្រើប្រាស់សម្រាប់ផ្តល់កំដៅដល់កូនមាន់នៅក្នុងរយៈ ៧-១០ថ្ងៃនៃជីវិតរបស់វា ។ ឆ្នាំងដី ឬក្អមដែលមានរន្ធតូចៗនៅសងខាង និងផ្នែកខាងលើ (ប្រសិនគ្មាន អាចយកទំរបាតចង្ក្រានគ្របពីលើឆ្នាំងដី ឬក្អមក៏បានដែរ) សម្រាប់ដុតធ្យូងនៅពេលយប់ ផ្តល់កំដៅដល់កូនមាន់ ក្នុងករណីគ្មានមេមាន់សម្រាប់ផ្តល់កំដៅ ។ ឆ្នាំងដី ឬក្អមដែលបានដុតធ្យូងឆេះហើយ ត្រូវបានដាក់នៅចំកណ្តាលទ្រុង ផ្ទាល់ដី ដើម្បីងាយស្រួលឱ្យកូនមាន់ទាំងអស់អាចដេកក្បែរនៅពេលដែលវាត្រូវការកំដៅ ។ ដើម្បីរក្សាកំដៅបានល្អនៅក្នុងទ្រុងកូនមាន់ ម្ចាស់មាន់ត្រូវបិទជុំវិញជើងទ្រុងកំពស់ ២៥-៣០ សង្ទីម៉ែត្រ ពីដី ដោយប្រើស្លឹកត្នោត ឬផ្ទាំងប្លាស្ទិក ។




ទ្រុងកូនមាន់ក្រាលដោយអង្កាម




ឆ្នាំងដីដាក់នៅថ្មពីរដុំចំកណ្តាលទ្រុងមាន់

**ចំណាំ :**

- ចងចាំថា មេមាន់ត្រូវក្រុងទ្រុងរហូតក្នុងរយៈពេល ៤៥ថ្ងៃ ហើយនៅអាយុ ៤៥ថ្ងៃនេះ កូនមាន់អាចមានទម្ងន់ ២០០-២៥០ ក្រាម ក្នុងមួយក្បាល ។
- នៅក្រោយ ៤៥ថ្ងៃ មេមាន់ត្រូវបានយកទៅដាក់កន្លែងផ្សេងដើម្បីចាប់ផ្ដើមផលិតកម្មស៊ុតជាថ្មី ។
- *នៅពេលរៀបចំវិធីផ្ដល់កំដៅនេះបាន កូនមាន់មិនត្រូវការមេវាទៀតទេ ។ ដូច្នេះម្ចាស់អាចបំបែកមេចេញបាន ។*

## ២.២.៤ បង្កើនផលិតភាពមេមាន់

មេមាន់ដែលបណ្ដើរកូនតិច ធ្វើឱ្យថយចុះផលិតភាពរបស់វា ។ នៅក្នុងប្រព័ន្ធចិញ្ចឹមមាន់ជាលក្ខណៈបុរាណ មេមាន់ចំណាយពេលបណ្ដើរកូនក្នុងរយៈពេល ៤៥-៦០ថ្ងៃ មុនចាប់ផ្ដើមផលិតស៊ុតសារជាថ្មី ។ នៅពេលដែលមានកូនមាន់ចំនួនតិចតួចញាស់ពីមេមាន់មួយ កូនមាន់ដែលញាស់នៅថ្ងៃប្រហាក់ប្រហែលគ្នា (៣-៥ថ្ងៃ ខុសគ្នា) អាចប្រមូលដាក់បញ្ចូលឱ្យមេមាន់មួយទៀតផ្ដល់កំដៅ ។

មេមាន់ដែលបានដកកូនចេញអស់ហើយ អាចជ្រលក់ទឹក ២ ដងក្នុងមួយថ្ងៃក្នុងរយៈពេល ៤-៥ថ្ងៃ ហើយមេមាន់ទាំងនោះ ត្រូវដាក់ទ្រុងក្នុងរយៈពេលនេះដែរ ។ មេមាន់ទាំងនោះ ក្នុងពេលឆាប់ៗអាចចាប់ផ្ដើមផលិតស៊ុតសារជាថ្មីវិញ ។

**ចំណាំ :**

- មេមាន់មួយក្បាលអាចផ្ដល់កំដៅដល់កូនមាន់ពី១៥-២០ក្បាល ហើយកូនមាន់ត្រូវការកំដៅជា ពិសេសក្នុងរយៈពេល ៧-១០ថ្ងៃ ក្រោយពេលញាស់ ។
- ក្រុងមេមាន់ដែលកូនត្រូវបានយកចេញឱ្យឆ្ងាយពីកូនរបស់វា ដើម្បីកុំឱ្យវាអាចស្ដាប់ឮកូនមាន់ស្រែក។ ធ្វើរបៀបនេះងាយឱ្យវាបំភ្លេចកូន ហើយចាប់ផ្ដើមពងសារជាថ្មី ។

វដ្ដផលិតកម្មមេមាន់ មានបង្ហាញនៅក្នុងដ្យាក្រាមខាងក្រោម:




**កូនមាន់ផលិតសរុបក្នុងមេមាន់ ៥ក្បាល ក្នុងមួយឆ្នាំ = ២០០ ក្បាល**

**ផលិតកម្មក្នុងមួយវដ្ដរបស់មេមាន់ ១ក្បាល**

## ២.៣ ការកែលំអចំណី និងការផ្ដល់ចំណី

ការចិញ្ចឹមមាន់តាមលក្ខណៈបុរាណ កូនមាន់ត្រូវបានផ្ដល់ចំណីអាហារដូចមាន់ធំៗដែរ ហើយការរកចំណីបានស៊ី អាស្រ័យទៅតាមរដូវតំបន់ និងការផ្ដល់ចំណីបន្ថែម ។ ការចិញ្ចឹមជាលក្ខណៈធម្មជាតិនេះ កូនមាន់ពឹងផ្អែកស្ទើរទាំងស្រុងទៅលើមេវាក្នុងការរកចំណីឱ្យវាស៊ី ។ ទន្ទឹមនេះការផ្ដល់ចំណីបន្ថែមដល់មាន់ មានតែស្រូវ និងអង្ករ ឬចុងអង្ករប៉ុណ្ណោះ ។ កូនមាន់នៅក្នុងអាយុ ១-៤៥ថ្ងៃ ត្រូវការចំណីដែលមានគុណភាពល្អ ជាពិសេសប្រូតេអ៊ីន ។ ភ្នាក់ងារផ្សព្វផ្សាយត្រូវធ្វើបង្ហាញដល់កសិករ នូវការរៀបចំចំណី ដែលមានគុណភាពអាចទទួលយកបានទៅតាមតម្រូវការរបស់សត្វ និងស្ថានភាពសេដ្ឋកិច្ចរបស់កសិករ ដោយប្រើប្រាស់ធនធានចំណីនៅក្នុងស្រុកឬប្រភេទចំណីថ្មីមានប្រូតេអ៊ីនខ្ពស់ដែលត្រូវណែនាំដល់កសិករ ។

ខាងក្រោមនេះ ជាជម្រើសនៃប្រភេទចំណីមួយចំនួនដែលភ្នាក់ងារផ្សព្វផ្សាយ អាចផ្តល់ជាការណែនាំ និងបង្ហាញដល់កសិករ ដើម្បីផ្សំជាចំណីសម្រាប់កូន និងមេមាន់ ។

- វារីរុក្ខជាតិ(រុក្ខជាតិដុះក្នុងទឹក) : ចកបាយទា ចកជើងតុកកែ និងត្រកួន
- គ្រាប់ធញ្ញជាតិ : សណ្តែកសៀង ស្រូវ កន្ទក់ និងចុងអង្ករ
- ចំណីមានប្រភពពីសត្វ : ម្សៅត្រី កូនត្រីតូចៗ និងកំពិស និងជន្លេន

## ២.៣.១ ចំណីមានប្រភពពីសត្វ

ផលិតផលមានដើមកំណើតពីសត្វ មានតម្លៃថ្លៃសម្រាប់ប្រើជាផ្នែកមួយនៃចំណីសម្រាប់សត្វ ។ ផ្ទុយទៅវិញបរិមាណនៃផលិតផលមានដើមកំណើតពីសត្វ អាចកាត់បន្ថយបាននៅពេលដែលមានធនធានចំណីផ្សេងទៀតអាចផលិតបាននៅក្នុងមូលដ្ឋានចូលមកជំនួសវិញនោះ ។ ប៉ុន្តែយើងគួរចងចាំផងដែរថា កូនមាន់នៅក្នុងដំណាក់កាលដំបូង (១-៤៥ថ្ងៃ) ត្រូវការចំណីដែលមានគុណភាពល្អដើម្បីមានលទ្ធភាពទាញយកសក្តានុពលលូតលាស់របស់មាន់ដែលធ្វើឱ្យវាមានសុខភាពល្អសម្រាប់ឆ្លងចូលទៅក្នុងដំណាក់កាលបំប៉ន ។

### ត្រី និងកំពិស

○ កូនត្រីតូចៗ និងកំពិស

នៅតំបន់មួយចំនួន កសិករអាចរកកូនត្រី កំពិស កូនក្តាម នៅតាមប្រឡាយ ស្រះ ត្រពាំង ថ្លុក វាលស្រែ តាមរយៈការជញ្ជាត់ អួសមុង ដាក់ទ្រូនៅរដូវវស្សា ដែលជាប្រភពប្រូតេអ៊ីនល្អបំផុតសម្រាប់កូនមាន់ ។ នៅពេលដែលបរិមាណរកបានមានចំនួនតិច កសិករអាចចិញ្ច្រាំវាឱ្យល្អិតមុន នឹងលាយជាមួយ ចំណីផ្សេងៗទៀត ។ ត្រីអាចឱ្យមាន់ស៊ីស្រស់ ឬជាម្សៅ ។ នៅពេលដែលត្រីសំបូរនោះកសិករអាចធ្វើម្សៅ ។ ដោយសារបរិមាណត្រូវការសម្រាប់កូនមាន់មានតិចតួច ដូច្នេះកសិករអាចហាលថ្ងៃរយៈពេល៣-៥ថ្ងៃ មុននឹងផលិតទៅជាម្សៅត្រីបាន ។ ហើយការផលិតម្សៅត្រីនោះ អាចប្រើប្រាស់ឧបករណ៍ក្នុងស្រុកមានដូចជា ត្បាល់ជាន់ ត្បាល់កិន ដែលកសិករប្រើសម្រាប់កិន ឬបុកស្រូវនោះ ។

○ ម្សៅត្រី

កសិករអាចទិញម្សៅត្រីនៅទីផ្សារនៅតាមទីរួមស្រុក ឬខេត្ត ។ គុណភាពអាស្រ័យទៅតាមប្រភេទត្រី ។ តម្លៃថោកដែលអាចទិញបាន គឺនៅដើមរដូវប្រាំង (វិច្ឆិកា-កុម្ភៈ) សម្រាប់ប្រភេទត្រីទឹកសាប ហើយកសិករអាចផលិតម្សៅត្រីដោយខ្លួនឯងដើម្បីធានាគុណភាព ។ ហេតុនេះហើយ កសិករគួរធ្វើផែនការទិញត្រីនៅពេលវេលានេះ សម្រាប់ជាប្រភពប្រូតេអ៊ីនដល់កូនមាន់ ។ ម្សៅត្រីជាប្រូតេអ៊ីនល្អបំផុតសម្រាប់ការលូតលាស់របស់កូនមាន់ ដោយសារគុណភាពរបស់វា ។

**ចំណាំ :**

- ម្សៅត្រីផលិតដោយត្រីសមុទ្រមានប្រូតេអ៊ីន ៥០០-៥៥០ ក្រាមក្នុងមួយគីឡូក្រាមម៉ាស់ស្ងួត ហើយម្សៅត្រីផលិតពីត្រីទឹកសាប មានប្រូតេអ៊ីន ៣៥០-៤០០ ក្រាមក្នុងមួយគីឡូក្រាមម៉ាស់ស្ងួត ។
- ដើម្បីពិនិត្យមើលថាតើម្សៅត្រីនោះមានលាយខ្សាច់ដែរឬអត់នោះ ត្រូវយកម្សៅត្រីប្រមាណមួយក្តាប់លាយជាមួយទឹក រក្សាទុក ២-៣នាទី ច្រាលទឹកផ្នែកខាងលើចោល រួចពិនិត្យមើលនៅបាតក្រោមផ្តិល ឬឧបករណ៍លាយនោះ តើមានខ្សាច់ដែរឬទេ ។

## ជន្លេន

ជន្លេនអាចរកបាននៅតាមទីកន្លែងដែលដីមានជីជាតិ (ដីពណ៌ខ្មៅ) និងសើម ហើយជន្លេនទាំងនោះនឹងចុះទៅក្នុងដីយ៉ាងជ្រៅនៅរដូវប្រាំង និងឡើងមកនៅលើផ្ទៃដីផ្នែកខាងលើវិញនៅរដូវវស្សា ឬនៅពេលមានទឹកច្រើន ឬលិច ។ ជន្លេនមានច្រើននៅក្នុងដីដែលមានជីជាតិច្រើន ជាពិសេសដីដែលស្ថិតនៅក្បែរផ្ទះ ។ ជន្លេនតូចៗអាចប្រើប្រាស់ជាប្រូតេអ៊ីនសម្រាប់កូនមាន់ លាយជាមួយសារធាតុផ្សំចំណីផ្សេងទៀត ។ កសិករក៏អាចផលិតជន្លេននៅតាមផ្ទះរបស់គាត់បានដែរ ។ ជន្លេនក្រហមមានប្រភពមកពីកាលីហ្វ័រញ៉ា បាននាំមកប្រទេសកម្ពុជា ៤-៥ឆ្នាំមុន សមស្របសម្រាប់ការចិញ្ចឹមនៅតាមផ្ទះរបស់កសិករ ។ ជន្លេនក្រហមកាលីហ្វ័រញ៉ាងាយស្រួលក្នុងការគ្រប់គ្រងជាងជន្លេនក្នុងស្រុក ។ ជន្លេនមានប្រូតេអ៊ីនខ្ពស់ ។

- ផលិតកម្មជន្លេន

ផលិតកម្មជន្លេនក្រហមកាលីហ្វ័រញ៉ា អាចធ្វើទៅបានដោយប្រើប្រាស់បច្ចេសទេសសាមញ្ញ និងការគ្រប់គ្រង ។ បច្ចេកទេស និងដំណាក់កាលត្រូវការសម្រាប់ការផលិតជន្លេនក្រហមកាលីហ្វ័រញ៉ា មានរៀបរាប់ខាងក្រោម :

**ផលិតកម្មនៅផ្ទាល់ដី**

- រៀបចំដីនៅទីកន្លែងមួយមានទួលខ្ពស់ដើម្បីជៀសវាងទឹកដក់ ប៉ុន្តែការខ្វះទឹកក៏កាត់បន្ថយលទ្ធភាពសម្រាប់ផលិតរបស់ជន្លេនក្រហមកាលីហ្វ័រញ៉ាដែរ ។
- យកដីលាយជាមួយលាមកគោ និងចំបើងដើម្បីពាសជុំវិញរណ្តៅឱ្យមានកំពស់ ៣០-៤០សម ពីដី ហើយមានទំហំ ៤ ម$^{២}$ ឬក៏អាចជីកទៅក្នុងដីវិញដោយប្រើប្រាស់ថង់ប្លាស្ទិកក្រាលក៏បាន ។
- ហាលថ្ងៃរយៈពេល ៣-៤ថ្ងៃ មុនចាប់ផ្តើមផលិតកម្មជន្លេន ។

- ដាក់លាមកគោ ឬជ្រូកចំនួន ១៥-២០គីឡូក្រាម ត្រូវបានដាក់ចូលទៅក្នុងរណ្ដៅ ហើយទើបដាក់លាមកដែលមានជន្លេន ០,៥គីឡូក្រាម នៅចំកណ្ដាលលាមកនោះ ។
- លាមកគោ ឬជ្រូកចំនួន ១៥-២០គីឡូក្រាមត្រូវបានដាក់បន្ថែមក្នុងកំឡុងពេល ១០-១៥ថ្ងៃម្ដង ហើយដាក់ក្បែរលាមកចាស់នោះ ។ ដើម្បីបង្កើនផលិតកម្មឱ្យលឿន ត្រូវយកលាមកគោដែលមានជន្លេនច្រើន ចំនួន ០,៥គីឡូក្រាមទៅដាក់ចំកណ្ដាលលាមកថ្មីនោះ ។

**ផលិតកម្មជន្លេននៅក្នុងកញ្ច្រែង ឬបង្គី**

- ដើម្បីភាពងាយស្រួលក្នុងការផលិត ហើយជៀសវាងការប៉ះពាល់ដល់ជន្លេននៅពេលធ្វើការបន្តពូជ កសិករគួរប្រើបង្គី ឬកញ្ច្រែងធ្វើនៅពីឫស្សី ឬសំភារៈផ្សេងទៀតដែលអាចទ្រលាមកបាន ផលិតនៅមូលដ្ឋានរបស់ខ្លួន ។
- កញ្ច្រែង ឬបង្គីនិមួយៗអាចដាក់លាមកស្រស់បាន ១០-១៥គីឡូក្រាម ។
- វិធីដាក់ជន្លេនធ្វើដូចគ្នានឹងផលិតផ្ទាល់ដីដែរ ។
- ក្រោយរយៈពេល ៤០-៥០ថ្ងៃ ដាក់កញ្ច្រែង ឬបង្គីដែលមានលាមកថ្មី (១០-១៥គក្រ) នៅលើកញ្ច្រែង ឬបង្គី ចាស់រយៈពេល ២-៣ថ្ងៃ មុននឹងចាប់យកជន្លេនពីកញ្ច្រែងចាស់ទៅ ប្រើប្រាស់ជាចំណីមាន់ ។ ធ្វើតាមវិធីនេះយើងសង្ឃឹមថា មានជន្លេនមួយភាគតូចបានឡើង ក្នុងកញ្ច្រែង ឬបង្គីថ្មី ដោយសារ មានក្លិនលាមកថ្មី ឬមួយយកលាមកដែលមានជន្លេនច្រើនចំនួន ០,៥គីឡូក្រាម ទៅដាក់កណ្ដាលលាមក នៃបង្គីថ្មីក៏បានដែរ ។

**ចំណាំ ៖**

- រណ្ដៅ ឬ កញ្ច្រែង ឬបង្គីត្រូវស្រោចទឹករៀងរាល់ ៣-៤ថ្ងៃម្ដង ជាពិសេសនៅរដូវប្រាំង ។
- លាមកជ្រូកល្អសម្រាប់ជាចំណីរបស់ជន្លេននេះ បើប្រៀបជាមួយលាមកគោ និងពពែ ។
- ក្នុងលាមកចំនួន ១,៥-២ គីឡូក្រាម អាចផលិត ២០-៥០ក្រាមជន្លេនស្រស់ និងកាកសំណល់ជាជីល្អសម្រាប់ដំណាំចំនួន ១ គីឡូក្រាម ក្នុងរយៈពេល ៣០-៤៥ថ្ងៃ ។
- កាកសំណល់លាមកក្រោយពីផលិតជន្លេនជាជីមួយមានគុណភាពខ្ពស់សម្រាប់ដំណាំ បន្លែ សំណាប ឬសួនផ្កា ។

  - ការផ្ដល់ជន្លេនឱ្យមាន់ស៊ី

ក្រោយពីបានប្រមូលរួចហើយ ជន្លេនត្រូវបានចិញ្ច្រាំជាកំណាត់តូចៗ រួចលាយជាមួយកន្ទក់ និងសារធាតុផ្សំផ្សេងទៀតមុនឱ្យកូនមាន់ស៊ី ។ កូនមាន់ខ្លះមានបញ្ហាស៊ីជន្លេនស្រស់ ដូច្នេះកសិករអាចហាលវារួច

ទើបលាយជាមួយចំណីផ្សេងទៀតមុនឱ្យកូនមាន់ស៊ី ។ ជន្លេនអាចជាប្រភពប្រូតេអ៊ីនសំខាន់សម្រាប់កូនមាន់នៅពេលដែលគេអាចផលិតវាបានគ្រប់គ្រាន់ ។

**ចំណាំ :**

- ជន្លេនមានប្រូតេអ៊ីនចំនួន ៣៥០-៤៣០ ក្រាមក្នុងមួយគីឡូក្រាមម៉ាស់ស្ងួត ឬ ៨០ក្រាមក្នុងមួយគីឡូក្រាមជន្លេនស្រស់ ។

## ២.៣.២ គ្រាប់ធញ្ញជាតិ

### គ្រាប់ និងម្សៅសណ្តែកសៀង

សណ្តែកសៀងត្រូវបានប្រើប្រាស់យ៉ាងច្រើនជាចំណីសត្វ ។ សណ្តែកសៀងគ្រាប់ ក៏ដូចជាម្សៅផងដែរ អាចប្រើប្រាស់ជាចំណីកូនមាន់ ។ តែចំពោះសណ្តែកសៀងជាម្សៅមិនទាន់មាននៅតាមខេត្តនានាទេ ។ ប្រសិនបើមាន ម្សៅសណ្តែកសៀង កសិករអាចប្រើប្រាស់សម្រាប់លាយចំណីកូនមាន់តែម្តង ។ គ្រាប់សណ្តែក សៀងឆៅ មិនអាចឱ្យកូនមាន់ស៊ីតែម្តងបានទេ ដោយសារវាមានជាតិពុល តែកសិករអាចធ្វើចំណីឱ្យកូនមាន់ ស៊ីបាន នៅពេលដែលចំអិនរួច ។

- ការចំអិនគ្រាប់សណ្តែកសៀងមុនឱ្យកូនមាន់ស៊ី

គ្រាប់សណ្តែកសៀង មានស្ទើរតែគ្រប់ទីកន្លែង នៅតាមទីផ្សារនៅថ្នាក់ស្រុក ឬខេត្ត ។ គ្រាប់សណ្តែកសៀងស្រស់អាចស្ងោរ ឬលីង។តែក្នុងចំណោមការចំអិនទាំង២ ការលីងទាក់ទាញកូនមាន់ឱ្យស៊ីចំណីបានច្រើន ហើយងាយស្រួលដល់កសិករក្នុងការចំអិន ។ ការស្ងោរអាចធ្វើទៅបាន តែទាមទាឱ្យធ្វើជា រៀងរាល់ថ្ងៃ ។

- កសិករត្រូវប្រើខ្ទះដើម្បីលីងគ្រាប់សណ្តែកសៀង ហើយត្រូវធ្វើយ៉ាងណាកុំឱ្យភ្លើងឆេះឆាបខ្លាំងឡើងមកលើ ដើម្បីជៀសវាងកំដៅខ្លាំងដែលធ្វើឱ្យខ្លោច ខូចគុណភាពប្រូតេអ៊ីននៅក្នុងសណ្តែកសៀង។ កសិករអាចពិនិត្យមើល នៅពេលដែលពណ៌ចាប់ផ្តើមប្តូរផ្លាស់ពីលឿងស្រាល ទៅក្រហមក្រម៉ៅ ហើយកសិករអាចសាកល្បងហូបមើល ប្រសិនបើគ្រាប់សណ្តែកស្រួយ ឈ្ងុយ អាចលើកខ្ទះសណ្តែកសៀងចេញពីភ្លើងបាន ។
- ក្រោយពេលលីងរួចភ្លាម សណ្តែកសៀងត្រូវបានបុកដោយត្បាល់ជាន់ដើម្បីផលិតជាម្សៅ ។

**ចំណាំ :**

- ការរៀបចំចំណីដោយប្រើសណ្តែកសៀង ត្រូវបានរៀបរាប់ជាលំអិតនៅក្នុងរូបមន្តខាងក្រោម ។
- សណ្តែកសៀងគ្រាប់មានប្រូតេអ៊ីន ៤៥០ក្រាម ក្នុងមួយគីឡូក្រាម ។

## គ្រាប់ពោត

ពោតពីរប្រភេទមានដាំនៅកម្ពុជា គឺពោតស និងពោតលឿង ។ ភាគច្រើនមានដាំនៅតាមបណ្តោយទន្លេមេគង្គ ។ ថ្មីៗនេះ ពោតលឿងត្រូវបានកសិករនៅភាគពាយ័ព្យនៃកម្ពុជា កំពុងដាំយ៉ាងច្រើន ដោយសារមានទីផ្សារនៅប្រទេសថៃ ។ ពោតត្រូវបានប្រើប្រាស់សំខាន់ជាប្រភពថាមពលសម្រាប់សត្វ ទោះបីវាមានសារធាតុចិញ្ចឹមផ្សេងទៀតដូចជា ប្រូតេអ៊ីន និងវីតាមីនក៏ដោយ ។ សម្រាប់ការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារនៅជនបទ ពោតនេះយើងមិនគួរយកមកប្រើប្រាស់ទេ ដោយសារវាមានតម្លៃទីផ្សារខ្ពស់ ។ តែប្រសិនបើកសិករមានដាំវិញ ពោតនោះក៏មានបរិមាណតិចតួចដែរ ដូច្នេះគួរយកទៅប្រើប្រាស់ជាចំណីអាហារមនុស្សប្រសើរជាង ។ ទាំងពោតស និងពោតលឿងមានប្រូតេអ៊ីនប្រមាណ ៧-៩ ភាគរយគិតជាម៉ាស់ស្ងួត ។

## ២.៣.៣ ទាវិរុក្ខជាតិ និងស្លឹករុក្ខជាតិផ្សេងទៀត

### ចកបាយទា (*Lemna ssp.*)

ចកបាយទាជារុក្ខជាតិដុះលើទឹកជាលក្ខណៈធម្មជាតិនៅតាម ត្រពាំង ស្រះ ប្រឡាយ និងវាលស្រែនៅរដូវវស្សា ។ ទឹកន្លែងដែលមានទឹកហើយនៅក្បែរផ្ទះ ធ្វើឱ្យចកដុះលឿន ។ ចកជាប្រភពធនធានប្រូតេអ៊ីនដែលមានគុណភាពល្អសម្រាប់កូនមាន់ ។ ក្រៅពីដុះតាមត្រពាំង ចកក៏អាចដាំដោយកសិករបានផងដែរ ។ ចកមានការដុះលូតលាស់លឿន មានទិន្នផលខ្ពស់ និងមានប្រូតេអ៊ីនខ្ពស់ (ប្រមាណ ៤០ភាគរយ) ពេលដុះនៅក្នុងទឹកដែលមានជីជាតិ និងជាចំណីដែលមានគុណភាពខ្ពស់សម្រាប់កូនមាន់ ។ ផ្ទុយទៅវិញចកបាយទាដែលដុះក្នុងទឹកដែលមានជីជាតិតិចតួចផលិតបានទិន្នផល ទាប ឬសវែង និងមានប្រូតេអ៊ីនទាប (២០-២៥ភាគរយក្នុងម៉ាស់ស្ងួត) ។





នៅរដូវវស្សា នៅពេលដែលទឹកមានជីជាតិខ្ពស់ ចកដុះលូតលាស់ដោយខ្លួនឯង

- ផលិតកម្មចកបាយទា

ភ្នាក់ងារផ្សព្វផ្សាយ អាចផ្តល់ការណែនាំដល់កសិករក្នុងការផលិតចកនៅក្រោមផ្ទះរបស់គេ ឬមួយនៅទីន្លែងមួយទំនេរនៅក្បែរផ្ទះ ។ ប្រព័ន្ធផលិតកម្មនេះ មានលក្ខណៈងាយស្រួលដោយប្រើប្រាស់សំភារៈដែលមាននៅក្នុងស្រុក ដូចបង្ហាញខាងក្រោម ៖

- កូនស្រះ ឬថ្លុកមួយដែលមានទំហំ២ គុណ ៣ ម និងជំរៅ ប្រមាណ ២០-២៥ សម ត្រូវបានក្រាលបាតជាមួយប្លាស្ទិកដើម្បីជៀសវាងការហូរជ្រាបជាពិសេសនៅរដូវប្រាំង ។
- ស្រះ ឬថ្លុកនេះអាចជីកនៅចន្លោះដើមឈើ ដែលផ្តល់ជាម្លប់តិចតួច ដែលធ្វើឱ្យទឹកត្រជាក់ ។
- លើកដីជាទំនប់នៅជុំវិញស្រះឬថ្លុក ដើម្បីទប់ស្កាត់កុំឱ្យទឹកភ្លៀងហូរកាត់នាំយកទាំងចកបាយទា និងជីជាតិពីស្រះ ។
- បញ្ចូលទឹកថែរក្សាកំពស់នៅត្រឹម ២០-២៥ សម ។
- យកលាមកគោ ឬលាមកជ្រូក ៧គីឡូក្រាម លាយជាមួយទឹក ៧គីឡូក្រាម មុននឹងដាក់បញ្ចូលទៅក្នុងស្រះ ។
- ដាក់ចកបាយទាចំនួន ១,៥ គីឡូក្រាម ទៅក្នុងស្រះនៅពេលចាប់ផ្តើមផលិតកម្ម ។
- ចកបាយទាត្រូវបានប្រមូលរៀងរាល់ថ្ងៃពីស្រះនោះ ។ បរិមាណដែលអាចប្រមូលប្រចាំថ្ងៃគឺ ០,៦-០,៧ គីឡូក្រាម ដែលអាចជាចំណីបន្ថែមសម្រាប់កូនមាន់អាយុ ១-៤៥ថ្ងៃ ចំនួន ៣០-៣៥ក្បាល ។



**ស្រះពាសស៊ីម៉ង់ដ៏ស្តើងសម្រាប់ផលិតកម្មចកបាយទា**



**ស្រះអាចសង់លើដីសម្រាប់ផលិតកម្មចកបាយទា**

**ចំណាំ ៖**

- ទឹកត្រូវបានបន្ថែមជាប្រចាំដើម្បីរក្សាកំពស់ ២០-២៥ សម ។
- ស្រះនេះត្រូវដាក់ជីរៀងរាល់ ៣-៤ថ្ងៃម្តង ក្នុងបរិមាណលើកឡើងខាងលើ ។

- ល្បាយ ទឹកជាមួយលាមកគោ ឬជ្រូកគួររក្សាទុកនៅក្នុងធុងមួយបិទជិត រយៈពេល ៧ ថ្ងៃ មុនស្រោចទៅក្នុងស្រះចក (កំប៉ុស្តិរាវ) ។ តាមរបៀបនេះ ធ្វើឱ្យជីជាតិនៅក្នុងលាមកគោរលាយនៅក្នុងទឹក ជាពិសេសអាសូត ដែលអាចឱ្យចកចាប់យកទៅប្រើប្រាស់ដោយងាយ ។
- ប្រសិនបើមានទឹកកាកសំណល់ឡជីវឧស្ម័ន កសិករអាចយកទៅប្រើផ្ទាល់តែម្តង ។

  - ការរៀបចំចកបាយទាជាចំណីមាន់

ចកមានសមាសភាពទឹកខ្ពស់ (៩៤-៩៦ភាគរយ) ។ នៅពេលដែលឱ្យស៊ីស្រស់ក្រោយពេលប្រមូលមកភ្លាមនោះ ធ្វើឱ្យកូនមាន់មានការលំបាកស៊ីចំណីឱ្យបានគ្រប់គ្រាន់ដើម្បីបំពេញតាមតម្រូវការរបស់វា ។ ដូច្នេះហើយ កសិករត្រូវយកចកទៅសំដិលក្រោមផ្ទះ ឬក្រោមម្លប់រយៈពេល ១២ ម៉ោងមុននឹងលាយជាមួយសមាសភាពផ្សំផ្សេងទៀត ។ ការសំដិលនេះ កាត់បន្ថយបរិមាណទឹកនៅក្នុងចកបាយទា ដែលធ្វើម៉ាស់ស្ងួតកើនឡើង ។



**ការដងចកបាយទាពីក្នុងស្រះ**



**ការរៀបចំចកបាយទាជាចំណីសម្រាប់កូនមាន់**

## ស្លឹកមរុម្ភ

មរុម្ភជាដើមឈើមួយប្រភេទមានកំពស់ជាមធ្យម តែអាចគ្រប់គ្រងជាដើមឈើផលិតស្លឹកបានដែរ ។ មរុម្ភអាចដាំដោយប្រើគ្រាប់ ឬមែកក៏បានដែរ ។ នៅប្រទេសកម្ពុជា មរុម្ភត្រូវបានប្រើប្រាស់តាំងពីបុរាណកាលមកជាបន្លែសម្រាប់ជាអាហារមនុស្ស ។ មរុម្ភត្រូវបានចាត់ទុកថា ជារុក្ខជាតិមួយដ៏អស្ចារ្យដោយសារមានសក្តានុពលនៃការប្រើប្រាស់ជា សារធាតុសម្រាប់សំអាតទឹក ថ្នាំប៉ូវសម្រាប់ស្ត្រីក្រោយសំរាលកូនរួច និងជាបន្លែ ។ល។ ដោយសារគុណភាពខ្ពស់នេះហើយ ស្លឹកមរុម្ភអាចជាប្រភពធនធានប្រូតេអ៊ីនយ៉ាងប្រសើរសម្រាប់កូនមាន់ពីអាយុ ១-៤៥ថ្ងៃ ។

## ស្លឹកមន

ស្លឹកមនត្រូវបានប្រើប្រាស់ជាចំណីសម្រាប់ដង្កូវនាង ។ នៅពេលបច្ចុប្បន្ននេះ សែលអាគ្រីតបានកំពុងប្រើប្រាស់ជាចំណីស្រស់ និងម្សៅសម្រាប់បំប៉នជ្រូក និងមាន់ ។ សម្រាប់កូនមាន់ ម្សៅស្លឹកមនអាចប្រើប្រាស់នៅ ក្នុងចំណីចំនួន ១០ ភាគរយ ។






**ការផលិតស្លឹកមនសម្រាប់ប្រើប្រាស់ជាចំណីសត្វ នៅ "សែលអាគ្រីត"**

**ចំណាំ :**

- ស្លឹកមនស្រស់មាន ប្រូតេអ៊ីន ៦០ក្រាមក្នុងមួយគីឡូក្រាម ។

## ស្លឹកដំឡូងឈើ

ដំឡូងឈើជាទូទៅ ត្រូវបានដាំសម្រាប់ផលិតមើម ហើយមានប្រទេសជាច្រើនបានទទួលស្គាល់ថាជាដំណាំសម្រាប់គ្រួសារក្រីក្រ ។ នៅស្ទើរតែគ្រប់តំបន់ទាំងអស់នៅប្រទេសកម្ពុជា មនុស្សបរិភោគស្លឹកដំឡូងឈើជាបន្លែ ។ ដំឡូងឈើអាចដាំសម្រាប់ផលិតមើម និងស្លឹកផងដែរ ។ ប្រសិនណាកសិករកាត់យកស្លឹកដំឡូងឈើ ២-៣ដងមុនដកយកមើម ធ្វើឱ្យផលិតកម្មមើមថយចុះ ២០-៣០ភាគរយ ។ សម្រាប់ផលិតកម្មខ្នាតតូច កសិករអាចដាំដំឡូងឈើនៅច្បារក្រោយផ្ទះ ជារបងបៃតង ឬជាដំណាំចំរុះជាមួយដំណាំផ្សេងទៀត ធ្វើតាមរបៀបនេះ កសិករអាចបេះយកស្លឹកដើម្បីធ្វើជាម្សៅស្លឹកដំឡូងឈើសម្រាប់កូនមាន់ ។ ស្លឹកដំឡូងឈើមានសារធាតុពុល ប៉ុន្តែអាចកាត់បន្ថយឱ្យនៅបរិមាណមួយតិចបំផុតដែលមិនប៉ះពាល់ដល់សត្វ តាមរយៈការហាល ស្ងោរ ផ្អាប់ ។ តែសម្រាប់មាន់ ស្លឹកអាចធ្វើជាម្សៅសម្រាប់លាយជាមួយចំណីផ្សេងទៀត ។



ដំឡូងឈើដាំនៅចំការក្រោយផ្ទះ



ដំឡូងឈើដែលដាំចំរុះជាមួយស្វរ

○ ការរៀបចំស្លឹកដំឡូងឈើជាចំណីមាន់

ស្លឹកដំឡូងឈើអាចជំនួសនៅក្នុងចំណីជាប្រភពប្រូតេអ៊ីនប្រមាណ ១៥ ភាគរយសម្រាប់មាន់ ។ ពិសោធន៍ដែលបានធ្វើនៅ "សែលអាគ្រីត" ប្រើប្រាស់ ៣០ភាគរយស្លឹកដំឡូងឈើនៅក្នុងចំណី ទទួលបានកំណើនទម្ងន់ប្រចាំថ្ងៃ ១០ក្រាម ក្នុងកូនមាន់មួយក្បាល ដែលលទ្ធផលនេះប្រហាក់ប្រហែលទៅនឹងមាន់ដែលឱ្យចំណីប្រូតេអ៊ីនមានប្រភពមកពីម្សៅត្រី ។ ខាងក្រោមនេះ ជាដំណាក់កាលសម្រាប់រៀបចំស្លឹកដំឡូងជាចំណី របស់កូនមាន់ :

- កាច់ដើមដំឡូងឈើផ្នែកខាងលើ ប្រមាណ ៣០-៤០ សម ។
- បេះស្លឹកចេញពីធាង និងដើម ។
- ហាលថ្ងៃស្លឹកដំឡូង ដែលបានបេះ រយៈពេល ៣-៤ថ្ងៃ រួចបុក ឬកិនជាម្សៅ ។
- លាយម្សៅស្លឹកដំឡូងជាមួយសមាសធាតុផ្សំចំណីផ្សេងទៀតដូចបានគណនានៅក្នុងជម្រើសទី ៥ ។



ដំឡូងឈើដែលបានដាំយកស្លឹកសម្រាប់ជាសំណើសត្វ



រៀបចំស្លឹកដំឡូងឈើសម្រាប់ហាលថ្ងៃ

**ចំណាំ ៖**

- ប្រើតែស្លឹកសម្រាប់ជាចំណីមាន់ ដោយយកធាង និងដើមខ្ចីសម្រាប់គោ-ក្របី ។
- បរិមាណស្លឹកដំឡូងឈើស្រស់ត្រូវការសម្រាប់មេមាន់ ៥ក្បាល និងកូនមាន់ចំនួន ២០០ក្បាល គឺ ២០-៣០គីឡូក្រាម ក្នុងមួយឆ្នាំ ដើម្បីផលិតម្សៅ ៥-៧,៥គីឡូក្រាម ដើម្បីលាយជាមួយសមាសធាតុចំណី ផ្សេងទៀត ។
- ស្លឹកត្រូវបានកិនភ្លាមៗក្រោយហាលថ្ងៃ ដោយសារវាស្រួយងាយស្រួលកិន ឬបុកជាម្សៅ ។


**ហាលថ្ងៃសំងួតស្លឹកដំឡូងឈើមុនកិន ឬបុកជាម្សៅ**


**លាយម្សៅស្លឹកដំឡូងឈើជាមួយសមាសធាតុចំណីផ្សេងទៀត**

## ត្រកួន

ត្រកួនជាដំណាំមួយងាយស្រួលដាំបំផុត ប៉ុន្តែត្រូវការទឹកសម្រាប់ស្រោចស្រព ។ ត្រកួនមានពីរប្រភេទ គឺត្រកួនគោក និងត្រកួនទឹក ដែលកសិករអាចដាំបាន ។ តែសម្រាប់ប្រើប្រាស់ជាចំណីកូនមាន់ មានតែស្លឹកវា ទេដែលល្អបំផុតនោះ ដោយសារមានបរិមាណប្រូតេអ៊ីនខ្ពស់ ។ ក្នុងករណីនេះ កសិករត្រូវផលិត ២២០គីឡូ ក្រាមត្រកួន (ដើម និងស្លឹក) ដើម្បីយកស្លឹកបាន ៧៤គីឡូក្រាម សម្រាប់ជាចំណីមេមាន់ ៥ក្បាល និងកូន មាន់ ២០០ក្បាលក្នុងមួយឆ្នាំ ។ ត្រកួនត្រូវការពេលវេលាប្រមាណ ៣៥-៤០ថ្ងៃប៉ុណ្ណោះ បើគិតចាប់ពីថ្ងៃដាំ រហូតដល់ថ្ងៃច្រូតកាត់ ។ ដូច្នេះបើមានការចាត់ចែងបានល្អ កសិករត្រូវការតែដីតូចប៉ុណ្ណោះដើម្បីផលិតត្រកួន សម្រាប់មេមាន់ ៥ក្បាល និងកូនមាន់ ២០០ក្បាលក្នុងមួយឆ្នាំ ។ ក្នុងករណីនេះ សម្រាប់ផលិតត្រកួន ដែលអាច ប្រើជាចំណីបន្ថែមនៅក្នុងបរិមាណចំណីសរុបនោះ មានលក្ខខណ្ឌមួយចំនួនដែលរៀបរាប់ ដូចខាងក្រោម ៖

- ផលិតកម្មត្រកួន

- ទំហំដីដែលត្រូវការ ៨ម² សម្រាប់ផលិតបានស្លឹកត្រកួន ៧,៤គីឡូក្រាម ឬ២២គីឡូក្រាមទាំងដើម និងស្លឹកក្នុងការច្រូតកាត់ម្តង ។
- ត្រូវការគ្រាប់ក្នុងករណីត្រកួនគោក និងទងសម្រាប់ត្រកួនទឹក ។
- ត្រូវការលាមកជ្រូក ២៥គីឡូក្រាម ឬ៥០គីឡូក្រាមលាមកគោសម្រាប់ទំហំដីខាងលើក្នុងមួយឆ្នាំ ។

**ចំណាំ :**

- ប្រសិនដាំត្រកួនគោក កសិករអាចកាត់បានពីរដង តែទិន្នផលថយចុះប្រមាណ ៥០ភាគរយ នៅពេលកាត់លើកទី ២ ។
- ដោយសារស្លឹកមានប្រូតេអ៊ីនខ្ពស់ កសិករគួរប្រើស្លឹក និងទងជាប់ត្រួយសម្រាប់ចំណីមាន់ ឯទងនៅសេសសល់អាចប្រើជាម្ហូបអាហារមនុស្ស ។
- ស្លឹកត្រកួនត្រូវបានចិញ្ច្រាំឱ្យបានល្អិតមុនលាយជាមួយសមាសធាតុចំណីផ្សេងទៀត ។




**ត្រកួនគោកស្រោចទឹកឡជីវឧស្ម័ននៅស្រុកទ្រាំង ខេត្តតាកែវ**



**ត្រកួនទឹកដាំនៅ “សែលអាគ្រីត”**

## ២.៣.៤ សង្ខេបជម្រើសសម្រាប់លាយចំណី

ភ្នាក់ងារផ្សព្វផ្សាយ អាចជ្រើសរើសយកជម្រើសមួយក្នុងចំណោមជម្រើសទាំងអស់ដែលបានផ្តល់ឱ្យខាងក្រោម អាស្រ័យទៅតាមធនធានដែលមាននៅទីកន្លែងនិមួយៗសម្រាប់ផ្សំជាចំណី នៅពេលដែលយក ’TIP’ នេះទៅអនុវត្ត ។ នៅពេលដែលសមាសធាតុផ្សំចំណីមានគ្រប់គ្រាន់ហើយ ភ្នាក់ងារផ្សព្វផ្សាយអាចណែនាំ និងធ្វើ បង្ហាញដល់កសិករនូវការរៀបចំចំណីប្រើប្រាស់ធនធានដែលមានស្រាប់ ឬក៏សមាសធាតុចំណីដែលកសិករអាចផលិតបាន ឬក៏មានតម្លៃថោកប្រសិនបើកសិករត្រូវទិញ ដើម្បីធ្វើយ៉ាងណាឱ្យពួកគេ ទទួលបានប្រាក់ចំណេញ ច្រើន ។ ទោះជាយ៉ាងណាក៏ដោយ ការរៀបចំចំណីត្រូវធានាគុណភាព ជាពិសេសទៅលើ

បរិមាណប្រូតេអ៊ីន ដែលអាចនៅចន្លោះ ១៧-២០ភាគរយសម្រាប់កូនមាន់អាយុ ១-៤៥ថ្ងៃ ដល់ការចិញ្ចឹមមាន់នៅជនបទ ។

ការរៀបចំចំណីលក្ខណៈសាមញ្ញដែលភ្ជាក់ងារផ្សព្វផ្សាយអាចយកទៅបង្ហាញកសិករ មានដូចខាងក្រោមនេះ :

## ជម្រើសសម្រាប់លាយចំណី ១០ គីឡូក្រាម (ក)

| សមាសធាតុផ្សំចំណី | បរិមាណ គិតជាគីឡូក្រាម | | | | | |
|---|---|---|---|---|---|---|
| | ជម្រើស ១ | | ជម្រើស ២ | | ជម្រើស ៣ | |
| | គក្រ | រង្វាល់ * | គក្រ | រង្វាល់ * | គក្រ | រង្វាល់ * |
| កន្ទក់ | ១,៩ | ១៦ កំប៉ុង | ៥ | ៤២ កំប៉ុង | ៥ | ៤២ កំប៉ុង |
| ចុងអង្ករ | ០,៧ | ៤ កំប៉ុង | ១,៤ | ៨ កំប៉ុង | ១,៤ | ៨ កំប៉ុង |
| ម្សៅត្រី | ០,៨ | ៤ កំប៉ុង | ២,៥ | ១២ កំប៉ុង | ២,៥ | ១២ កំប៉ុង |
| ចកបាយទា** | ៦,៦ | ៣៣ ល្អី | | | | |
| ស្លឹកមរុម្ម | | | ១ | ១៣ កំប៉ុង | | |
| ស្លឹកមន | | | | | ១ | ១៣ កំប៉ុង |
| អំបិល | ០,០២ | | ០,០៤ | | ០,០៤ | |
| ព្រីមិក (PREMIX) | ០,០២ | | ០,០៤ | | ០,០៤ | |
| ប្រូតេអ៊ីន % | ១៧ | | ១៧ | | ១៧ | |

## ជម្រើសសម្រាប់លាយចំណី ១០ គីឡូក្រាម (ខ)

| សមាសធាតុផ្សំចំណី | បរិមាណ គិតជាគីឡូក្រាម | | | | | |
|---|---|---|---|---|---|---|
| | ជម្រើស ៤ | | ជម្រើស ៥ | | ជម្រើស ៦ | |
| | គក្រ | រង្វាល់ * | គក្រ | រង្វាល់ * | គក្រ | រង្វាល់ * |
| កន្ទក់ | ១,៩ | ១៦ កំប៉ុង | ៤,៤ | ៣៧ កំប៉ុង | ១,៧ | ១៤ កំប៉ុង |
| ចុងអង្ករ | ០,៦ | ៤ កំប៉ុង | ១,៣ | ៨ កំប៉ុង | ០,៥ | ៣ កំប៉ុង |
| សណ្តែកសៀង | ០,៨ | ៣,៥ កំប៉ុង | ១,៣ | ៥,៥ កំប៉ុង | ០,៥ | ២,៥ កំប៉ុង |
| ជន្លេន | | | ១,៦ | ៦,៥ កំប៉ុង | | |
| ចកបាយទា** | ៦,៧ | ៣៣ ល្អី | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| **ម្សៅស្លឹកដំឡូងឈើ** | | | ១,៣ | **១៦ កំប៉ុង** | | |
| **ស្លឹកត្រកួន** | | | | | ៧,២ | ក |
| **អំបិល** | ០,០២ | | ០,០៤ | | ០,០២ | |
| **ព្រីម៉ិក(PREMIX)** | ០,០២ | | ០,០៤ | | ០,០២ | |
| **ប្រូតេអ៊ីន %** | ១៨ | | ១៨ | | ១៨ | |

* រង្វាល់(កំប៉ុង)ប្រើកំប៉ុងទឹកដោះគោ ដែលនិយាយប្រើសម្រាប់វាល់អង្ករ និងល្អីវាល់អង្ករ ១២គីឡូក្រាម ។

**នៅពេលដែលមិនមានថ្ងៃក្តៅខ្លាំង ការហាលចកមិនទទួលបានលទ្ធផលល្អទេ ដែលធ្វើឱ្យចកខូចគុណភាព ។ នៅក្នុងករណីនេះ ចកក្នុងបរិមាណតិចតួចត្រូវបានផង និងសំដិលថ្ងៃរយៈពេល ១២ម៉ោង ដើម្បីកាត់បន្ថយបរិមាណទឹក (៦០-៨០ភាគរយ) បន្ទាប់មកចកបាយទាដែលបានសំដិលនោះ អាចយកទៅលាយជាមួយ សមាសធាតុចំណីផ្សេងទៀត ។

ក, ត្រកួនដែលហាលស្ងួត មិនគួរប្រើជាចំណីមាន់នោះទេ ។ ត្រកួនអាចងាយស្រួលឱ្យមាន់ស៊ីនៅពេលហាន់ត្រកួនស្រស់ឱ្យតូចៗ មុននឹងលាយជាមួយបរិមាណចំណី (កន្ទក់ ចុងអង្ករ និងសណ្តែកសៀង) ដែលត្រូវឱ្យមាន់ស៊ីក្នុងមួយថ្ងៃ ។

*សារធាតុគីមីនៃសមាសធាតុផ្សំចំណីដែលបានប្រើប្រាស់នៅក្នុងជម្រើសទាំង ៦ ខាងលើ

| **សមាសធាតុផ្សំចំណី** | **ម៉ាស់ស្ងួត** (%) | **ប្រូតេអ៊ីន** (%) |
|---|---|---|
| **ចុងអង្ករ** | ៨៨ | ៨ |
| **កន្ទក់** | ៨៨ | ១១ |
| **ម្សៅត្រី** | ៨៨ | ៣៥ |
| **ត្រីស្រស់** | ២៥ | ៥០ |
| **សណ្តែកសៀង** | ៨៩ | ៤៣ |
| **ជន្លេន** | ២៥ | ៤០ |
| **ចកបាយទា** | ៥ | ៣៥ |
| **ស្លឹកត្រកួន** | ១២ | ៣០,៦ |
| **ម្សៅស្លឹកមរុម្ម** | ៨៥ | ២៤ |
| **ម្សៅស្លឹកមន** | ៨៨ | ២៥ |
| **ម្សៅស្លឹកដំឡូងឈើ** | ៨៨ | ២២ |

*ទិន្នន័យវិភាគនៅមន្ទីរពិសោធន៍នៃមជ្ឈមណ្ឌលអភិវឌ្ឍន៍ការចិញ្ចឹមសត្វ និងកសិកម្ម "សែលអាគ្រីត"

## ២.៤ ការចាក់ថ្នាំការពារ និងផ្សេងៗ

កូនមាន់ដែលញាស់មកបាន ១-៤៥ ថ្ងៃ ត្រូវចាក់ថ្នាំការពារជម្ងឺអុតមាន់ និងញូកាស់ ហើយប្រភេទវ៉ាក់សាំងទាំងពីរមានលក់នៅប្រទេសកម្ពុជា ។ មានវ៉ាក់សាំងញូកាស់ប្រភេទថ្មី អាយធូ (I2) ផលិតនៅប្រទេសវៀតណាមមានលក់នៅតាមឱសថស្ថានពេទ្យសត្វនៅតាមខេត្ត និងស្រុកមួយចំនួន ។ វ៉ាក់សាំងអាយធូមួយដបតូចមាន ១៥-២៥ក៏រិត ដែលសមស្របណាស់សម្រាប់សហគមន៏ជនបទ ។ ក្រៅពីនេះ វ៉ាក់សាំងអាយធូ អាចរក្សាទុកនៅក្នុងសីតុណ្ហភាព ២៨អង្សារសេនៅក្នុងទឹងផឹត រយៈពេល ២ខែ ក្រោយពីចេញពីទូរទឹកកក ។ ព័ត៏មានបន្ថែមលើការងារនេះ ពិនិត្យមើល ’TIP’ ផ្សេងទៀត ដែលរៀបរាប់ពីការចាក់វ៉ាក់សាំងនេះ ។

### ពេលវេលានៃការចាក់ថ្នាំការពារ

| (ជម្រើស ១) | | |
|---|---|---|
| **អាយុ (ថ្ងៃ)** | **វ៉ាក់សាំង** | **ការផ្តល់** |
| ៥ | ញូកាស F ឬ B1 | បន្តក់ក្នុងភ្នែក ឬច្រមុះ * |
| ១០ | អុត | ជួសនៅស្បែកផ្ទាំងស្លាប |
| ២០ | ញូកាស F ឬ B1 | បន្តក់ក្នុងភ្នែក ឬច្រមុះ |
| ៤០ | ញូកាស La sota | លាយទឹកផឹក * |
| +៦០ | ញូកាស M | ក្នុងសាច់ដុំ |

| (ជម្រើស ២) | | |
|---|---|---|
| **អាយុ (ថ្ងៃ)** | **វ៉ាក់សាំង** | **ការផ្តល់** |
| ៥ | ញូកាស I2 | បន្តក់ក្នុងភ្នែក |
| ១០ | អុត | ជួសនៅស្បែកផ្ទាំងស្លាប |
| +៤៥ | អាសន្នរោគ ** | ក្នុងសាច់ដុំ |

* បរិមាណនៃការផ្តល់វ៉ាក់សាំង សូមមើលលំអិតនៅក្នុង បទដ្ឋានអនុវត្តបច្ចេកវិទ្យាស្តីពី ការគ្រប់គ្រងនិងការពារជំងឺញ៉ូកាស

** កាលពីពីរឆ្នាំមុន ផលិតផលវ៉ាក់សាំងនេះត្រូវបានឈប់ប្រើប្រាស់ ហើយវាគ្មានលក់នៅតាមទីផ្សារទេ ទោះជាយ៉ាងនេះក្តី ក៏យើងបានផ្តល់អនុសាសន៏អោយធ្វើអនាម័យសំអាតទីធ្លាទ្រុង រួមមាន ស្នូកទឹក និងចំណី អោយបានស្អាត និង ទឹកសម្រាប់មាន់ផឹក ទើបអាចការពារទប់ទល់នឹងជម្ងឺនេះបាន ។

នៅក្នុងសំបុកមាន់ និងនៅលើមេមាន់មានស្រមើរជាច្រើនដែលអាចខាំធ្វើឱ្យមានស្នាមរបួសឈាម នៅលើស្បែកមាន់ ។ ហើយស្រមើរដែលបង្កបញ្ហាខ្លាំងនោះ នៅពេលវាមានវ័យក្មេងនៅឡើយ ហើយវារំខានពិសេសតែនៅលើមេមាន់ ។ ទន្ទឹមនេះដែរ វាក៏អាចរំខានដល់កសិករដែលចូលធ្វើការងារក្នុងទ្រុងមាន់ផងដែរ ។ ដូច្នេះដើម្បីការពារកុំឱ្យមានស្រមើរទាំងនោះ កសិករត្រូវដាក់ថ្នាំជក់ ហើយជាថ្នាំខ្លាំងទៅក្នុងសំបុក មាន់ក្រាបពងដើម្បីជៀសវាងស្រមើរនេះ ។

### ២.៤.១ ជម្ងឺគ្រុនបក្សី

ជម្ងឺផ្តាសាយបក្សី (HPAI) ដែលបណ្តាលមកពី មេរោគម្យ៉ាងឈ្មោះ H5N1 ត្រូវបានគេកំណត់អត្តសញ្ញាណឃើញជាលើកដំបូងនៅប្រទេសកម្ពុជា កាលពីថ្ងៃទី ២៣ ខែមករា ឆ្នាំ២០០៤ ។ រហូតមកទល់ពេលនេះ ជម្ងឺផ្តាសាយបក្សីបានកើតឡើងចំនួនដប់ប្រាំករណីរួចមកហើយ ដែលមួយករណីនៅទីក្រុងភ្នំពេញ និងនៅក្នុងបណ្តាខេត្តចំនួនប្រាំ រួមមានខេត្ត តាកែវ កណ្តាល សៀមរាប កំពង់ចាម និងខេត្តកំពត ។ មនុស្សបួននាក់ត្រូវបានគេរាយការណ៏ថា បានស្លាប់ដោយសារជម្ងឺនេះនៅក្នុងស្រុកកំពង់ត្រាចខេត្តកំពត ដែលមានព្រំប្រទល់ជាប់ជាមួយនឹងប្រទេសវៀតណាម ។ បក្សីដែលកើតជម្ងឺនេះ គឺមានរោគសញ្ញាជាច្រើនដូចជា វាមិនស៊ីអាហារ ស្លាបឡើងរឹង គ្រុនក្តៅ ខ្សោយកំលាំងរាគរូស ស្រេកទឹកខ្លាំង និងហើម ។ ជម្ងឺផ្តាសាយបក្សី (HPAI) អាចបណ្តាលអោយមានការបាត់បង់ច្រើន ហើយវាក៏អាចជះឥទ្ធិពលដល់សុខភាពមនុស្សទៀតផង ។ បច្ចុប្បន្ននេះប្រទេសកម្ពុជាមិនទាន់មានវ៉ាក់សាំងសម្រាប់ការពារបក្សីពីជម្ងឺនេះនៅឡើយទេ ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយដើម្បីកាត់បន្ថយការប៉ះពាល់បក្សាបក្សី ដែលមានជម្ងឺនេះគេគួរតែមានវិធានការប្រព័ន្ធការពារជីវសាស្រ្ត ។

សម្រាប់ព័ត៏មានបន្ថែម សូមទំនាក់ទំនង នាយកដ្ឋាន ផលិតកម្មនិងបសុព្យាបាល ។

## ២.៥ ផលចំណេញផ្នែកសេដ្ឋកិច្ច

ការសន្មតនានាដើម្បីវិភាគសេដ្ឋកិច្ចមានដូចខាងក្រោម :

- នៅក្នុងប្រព័ន្ធចិញ្ចឹមមាន់តាមលក្ខណៈបុរាណ មាន់ត្រូវបានផ្តល់ចំណីឱ្យនៅពេលព្រឹក ឬនៅពេលល្ងាចមានស្រូវ ឬអង្ករប្រមាណមួយកំប៉ុងដែលមានទម្ងន់ ២០០-២៥០ក្រាម ហើយបរិមាណនៃការឱ្យស៊ីនេះក៏អាស្រ័យទៅលើចំនួនមាន់ផងដែរ ។
- តែភាគច្រើនការផ្តល់ស្រូវសម្រាប់មេមាន់ និងមាន់ជំទង់ ហើយចុងអង្ករ ឬជួនកាលកន្ទក់សម្រាប់កូនមាន់ ។

- តម្លៃទ្រុងមាន់មិនបានដាក់បញ្ចូលនៅក្នុងការចិញ្ចឹមមាន់តាមប្រព័ន្ធ បុរាណនេះទេ ដោយសារភាគច្រើនកសិករឱ្យមាន់ដេកនៅលើដើមឈើ និងក្រោមផ្ទះ ។
- តែដើម្បីអាចធ្វើការប្រៀបធៀបបាន មាន់ចិញ្ចឹមនៅក្នុងប្រព័ន្ធទាំងពីរ "បុរាណ និងកែលំអ" ត្រូវបញ្ចូលការចាក់វ៉ាក់សាំងប្រឆាំង នឹងជម្ងឺមាន់សំខាន់ៗ ។
- ការគណនាផ្អែកទៅលើចំនួនមេមាន់ ៥ក្បាល ដែលមនុស្សម្នាក់ជាអ្នកទទួលខុសត្រូវ ប៉ុន្តែដើម្បីធ្វើឱ្យការប្រើប្រាស់ពលកម្មគ្រួសារឱ្យមានប្រសិទ្ធិភាពនេះ ភ្នាក់ងារផ្សព្វផ្សាយគួរលើកទឹកចិត្តឱ្យកសិករចិញ្ចឹមមេមាន់ពី ១០-១៥ក្បាល ក្នុងមួយគ្រួសារ ធ្វើដូច្នេះនាំឱ្យមានការទាក់ទាញកសិករច្រើន ដោយសារពួកគេអាចរកប្រាក់ ចំណូលបានច្រើនពីការអនុវត្តន៍ ’TIP’ នេះ ។
- ជម្រើសទី ១ នៃចំណីផ្សំដែលបង្ហាញខាងលើ ត្រូវបានយកមកធ្វើការគណនាលើផលប្រយោជន៍សេដ្ឋកិច្ច ។ ភ្នាក់ងារផ្សព្វផ្សាយ អាចប្រើប្រាស់ឧទាហរណ៍នេះ ដើម្បីគណនាទៅតាមប្រភេទចំណីដូចមាននៅជម្រើសផ្សេងៗទៀតដែលសមស្របសម្រាប់កសិករនៅតាមតំបន់និមួយៗនៅប្រទេសកម្ពុជា ។ ចំណែកឯសមាសធាតុដែលបានយកមករៀបចំជាចំណីនៅក្នុងជម្រើសទាំង ៦ នោះ ជាទូទៅកសិករអាចទិញ និងផលិតបាននៅតាមតំបន់របស់ខ្លួនស្ទើរតែគ្រប់កន្លែងទាំងអស់នៅប្រទេសកម្ពុជា ។
- គោលបំណងនៃការកែលំអការចញ្ចឹមមាន់នៅដំណាក់កាលនេះ គឺធានាឱ្យអត្រាងាប់របស់កូនមាន់ថយចុះ និងបង្កើនផលិតភាពរបស់មេមាន់ផងដែរ ។ សំរេចជោគជ័យលើអ្វីដែលលើកឡើងទាំងអស់នេះ ធានាផលិតកូនមាន់ដែលមានសុខភាពល្អសម្រាប់បំប៉នយកសាច់
ដូច្នេះធ្វើឱ្យផលិតកម្មធានាបានប្រាក់ចំណេញច្រើន និងធ្វើឱ្យមាននិរន្តរភាព ។

**ឧទាហរណ៍ : ប្រៀបធៀបសេដ្ឋកិច្ចនៃការចិញ្ចឹមមាន់លក្ខណៈបុរាណ និងការកែលំអលើការផ្តល់ចំណី និងគ្រប់គ្រងមេមាន់ និងកូនមាន់ពូជក្នុងស្រុកសម្រាប់មួយគ្រួសារក្នុងមួយឆ្នាំ (ប្រាក់ទាំងអស់គិតជារៀល)**

| | ទំលាប់កសិករ | | | កែលំអ | | |
|---|---|---|---|---|---|---|
| **ប្រាក់ចំណូល** | **ទិន្នផល ក្បា/ឆ្នាំ** | **តម្លៃ រៀល/ឯកតា** | **ចំណូល ក្បា/ឆ្នាំ** | **ទិន្នផល ក្បា/ឆ្នាំ** | **តម្លៃ រៀល/ឯកតា** | **ចំណូល ក្បា/ឆ្នាំ** |
| កូនមាន់ | ៧៥ក្បា | ២៥០០ | ១៨៧៥០០ | ២០០ក្បា | ២៥០០ | ៥០០០០០ |
| មេមាន់ | ៧,៥គ.ឡ | ៨០០០ | ៦០០០០ | ៧,៥គ.ឡ | ៨០០០ | ៦០០០០ |
| | | សរុប | ២៤៧៥០០ | | | ៥៦០០០០ |
| ការចំណាយ | បរិមាណមាន់/ឆ្នាំ | តម្លៃ រៀល/ឯកតា | ចំណាយក្បា/ឆ្នាំ | បរិមាណមាន់/ឆ្នាំ | តម្លៃ រៀល/ឯកតា | ចំណាយក្បា/ឆ្នាំ |
| មេមាន់ | ៧,៥គ.ឡ | ៨០០០ | ៦០០០០ | ៧,៥គ.ឡ | ៨០០០ | ៦០០០០ |
| **ការប្រើប្រាស់ចំណីជម្រើសទី ១** | | | | | | |
| ស្រូវ | ៥៥ | ៥៥០ | ៤០១៥០ | | | |
| ចុងអង្ករ | ២៧ | ៨០០ | ២១៦០០ | ២៤ | ៨០០ | ១៩២០០ |
| កន្ទក់ | | | | ៩ | ៥៥០ | ៤៩៥០ |
| ម្សៅត្រី | | | | ៩,៥ | ២០០០ | ១៩០០០ |
| ចកបាយទា | | | | ៨៤ | ៥០ | ៤២០០ |
| អំបិល | | | | ០,២ | ៤០០ | ៨០ |
| ព្រីម៉ិក (Premix) | | | | ០,២ | ១០០០០ | ២០០០ |
| វ៉ាក់សាំង | ១៦០ | ១០០ | ១៦០០០ | ១៦០ | ១០០ | ១៦០០០ |
| ទ្រុង | | | | * | | ៣៩៦០០ |
| របងរាំងកូនមាន់ | | | | | | ៤០០០០ |
| | | ចំណាយប្រាក់សរុប | ១៣៧៧៥០ | | | ២០៥០៣០ |
| **ប្រាក់ចំណេញ+ពលកម្ម** | | | ១០៩៧៥០ | | | ៣៥៤៩៧០ |
| **ចំណាយមិនមែនសាច់ប្រាក់** | | | | | | |
| ពលកម្ម | ២៣ | ៤០០០ | ៩២០០០ | ៤៥ | ៤០០០ | ១៨០០០០ |
| | | **ចំណាយសរុប** | ២០១៧៥០ | | | ៣៨៥០៣០ |
| | | **ប្រាក់ចំណេញ** | ៤៥៧៥០ | | | ១៧៤៩៧០ |
| | | **ប្រាក់ទទួលបានគិតជាពលកម្មក្នុងមួយថ្ងៃ** | ៤៧៧០ | | | ៧៨៦០ |
| | | | | | **ប្រាក់ចំណេញសុទ្ធពី មេមាន់ ៥ ក្បាល** | ១២៩២២០ |
| | | | | | **បង្កើនចំណូលគ្រួសារតាមរយៈ មេមាន់ ៥ ក្បាល** | ២៤៥២២០ |

*យើងគិតថាទ្រុងមាន់មួយដែលបានសាងសង់ អាចប្រើប្រាស់រយៈ ៣ឆ្នាំ ដូច្នេះជាតម្លៃរំលួស ប្រចាំឆ្នាំ គឺ ៣៣ភាគរយ សម្រាប់គណនាលើការវិភាគសេដ្ឋកិច្ច ។

## ២.៦ ផលប៉ះពាល់លើបរិស្ថាន

ដោយសារបច្ចេកវិទ្យាដែលបានលើកនៅក្នុង ”TIP” នេះ ត្រូវបានគ្រប់គ្រងតាមលក្ខណៈធម្មជាតិ ដោយប្រើប្រាស់ផល និងអនុផលកសិកម្ម ឬអ្វីដែលគាត់ផលិត ហេតុដូច្នេះហើយ ធ្វើឱ្យមានផលប៉ះពាល់វិជ្ជមានមួយចំនួនសម្រាប់បរិស្ថាន ។

មាន់ចិញ្ចឹមក្នុងទ្រុង មិនត្រឹមតែការពារទល់នឹងគ្រោះថ្នាក់មួយចំនួនប៉ុណ្ណោះទេ ប៉ុន្តែអាចការពារមាន់មិនឱ្យធ្វើការប៉ះពាល់ដល់ផលប្រយោជន៍កសិករផ្សេងទៀត ដូចជាការករកាយសួនបន្លែ ។

ការចិញ្ចឹមជន្លេនជាវិធីមួយមានប្រសិទ្ធិខ្ពស់ណាស់ក្នុងការប្រើប្រាស់លាមកសត្វដែលមានអាស្សូតខ្ពស់ឱ្យក្លាយជាជីមួយមានជីជាតិរលាយយឺតៗសម្រាប់ដំណាំ ។ វិធីនេះអាចកាត់បន្ថយផលវិបាកបរិស្ថានដោយសារមានជីជាតិច្រើន បានភាយចេញពីប្រព័ន្ធកសិដ្ឋាន និងធ្វើឱ្យស្រះ ទន្លេ កខ្វក់ ។ល។ តែនឹងផលិតអាហារមួយដែលមានប្រូតេអ៊ីនយ៉ាងល្អ ។

---

## ៣. ការណែនាំលើការងារផ្សព្វផ្សាយ

### ៣.១ វិធីសាស្ត្រនៃការផ្សព្វផ្សាយ

ជាទូទៅកសិកររក្សាទុកមេមាន់សម្រាប់បន្តពូជ និងបំប៉នផងដែរ ហេតុដូច្នេះហើយវាជាការងាយស្រួល ក្នុងការរៀបចំកសិករជាក្រុម ជាពិសេសអ្នកដែលមានការចាប់អារម្មណ៍លើការសាកល្បង ’TIP’ នេះ ។ ការធ្វើបង្ហាញអាចរៀបចំឡើងពី ៥-១០ កន្លែងនៅក្នុងភូមិមួយ អាស្រ័យទៅតាមចំនួនគ្រួសារកសិករ ដង់ស៊ីតេ និងទំហំរបស់ភូមិ ។ ដើម្បីធ្វើឱ្យការផ្សព្វផ្សាយមានការរីកសាយល្អនោះ គឺត្រូវធ្វើយ៉ាងណាឱ្យកសិករចូលរួមម្នាក់ជ្រើសរើសដៃគូរបស់គេ ៥នាក់ទៀតសម្រាប់រៀនជាមួយគ្នា ។ ភ្នាក់ងារផ្សព្វផ្សាយជួបប្រជុំជាមួយក្រុមកសិករនេះរៀងរាល់សប្តាហ៍ដើម្បីពិនិត្យតាមដានការធ្វើបង្ហាញនេះ ហើយជាមួយគ្នានោះដែរ ពិភាក្សាបញ្ហា ឬប្រធានបទពាក់ព័ន្ធនានា ទៅលើការអនុវត្តន៍ ’TIP’ នេះ ។

វិធីសាស្ត្រសម្រាប់ការអនុវត្តន៍ ’TIP’ នេះ ផ្អែកលើការធ្វើបង្ហាញតាមគោលដៅគ្រួសារនិមួយៗ ប៉ុន្តែការជួបប្រជុំ និងពិភាក្សារៀងរាល់សប្តាហ៍ ត្រូវធ្វើជាក្រុមធំនៅក្នុងភូមិដែលមាន ការចូលរួមទាំងកសិករធ្វើបង្ហាញ និងដៃគូររបស់គេ ។

ដ្យាក្រាមនៃយុទ្ធសាស្ត្ររីកសាយលើការងារផ្សព្វផ្សាយនៃ TIP នេះ



**ដំណាក់កាល និងការណែនាំ :** ដំណាក់កាល និងបែបបទនានាក្នុងការរៀបចំ អនុវត្ត និងវាយតម្លៃទៅលើ 'TIP' នេះ មានរៀបចំក្បោះក្បាយនៅខាងក្រោម :

<u>ការជ្រើសរើសទីតាំង</u> :

ដោយសារតែ 'TIP' នេះ អាចសមស្របស្ទើរតែគ្រប់តំបន់ទាំងអស់នៃប្រទេសកម្ពុជា ដូច្នេះមិនមានជាលក្ខណៈវិនិច្ឆ័យអ្វីធំដុំសម្រាប់ការជ្រើសរើសនោះឡើយ ។ ទោះបីយ៉ាងនេះក៏ដោយ ភូមិដែលមានផ្ទះនៅដាច់ៗ ឆ្ងាយពីគ្នា គួរត្រូវបានជ្រើសរើសដើម្បីសាកល្បង 'TIP' នេះ ជាដំបូងសិន ដើម្បីងាយស្រួលក្នុងការរៀបចំ និងទីកន្លែង សម្រាប់ផលិតចំណីមាន់ទៀតផង ។

<u>ការជ្រើសរើសកសិករ និងការរៀបចំ</u> :

ដើម្បីធ្វើឱ្យតម្លៃ ការងារផ្សព្វផ្សាយនេះ អាចទទួលយកបាន និងបង្កើនប្រសិទ្ធិភាពនៃការប្រើធនធាននោះ ភ្នាក់ងារផ្សព្វផ្សាយគួរ :

- ជ្រើសរើសកសិករចាប់អារម្មណ៍ និងសកម្ម ៥-១០នាក់ នៅក្នុងភូមិមួយ (ចំនួនអាស្រ័យលើចំនួនគ្រួសារដង់ស៊ីតេ និងទំហំភូមិ) ។ កសិករចូលរួមត្រូវមានមេមាន់យ៉ាងហោចណាស់ ៥ក្បាល សម្រាប់ចូលរួមអនុវត្ត 'TIP' នេះ ។
- កសិករដែលបានជ្រើសរើសមានផ្ទះនៅឆ្ងាយៗពីគ្នានៅក្នុងភូមិ ដើម្បីធ្វើឱ្យការផ្សព្វផ្សាយចែកចាយដល់មនុស្សច្រើន ។ កសិករចូលរួមធ្លាប់មានបទពិសោធន៍លើការចិញ្ចឹមមាន់ខ្លះ និងមានចិត្តចង់ចូលរួម ។
- ជាលក្ខខណ្ឌសម្រាប់ចូលរួមនៅក្នុងការអនុវត្តន៍ 'TIP' នេះ កសិករដែលបានជ្រើសរើសត្រូវរកដៃគូចំនួន ៥នាក់ ដែលរស់នៅជុំវិញផ្ទះខ្លួនដើម្បីធ្វើការរៀនសូត្ររួមគ្នា ។
- ដើម្បីលើកទឹកចិត្តដល់ការចូលរួមរបស់កសិករជ្រើសរើស និងចែករំលែកបទពិសោធន៍ដល់អ្នកដទៃមានសំភារៈមួយ ចំនួនដែលផ្តល់ឱ្យកសិករដូចជាសមាសធាតុចំណីដែលគាត់ មិនអាចផលិតនៅក្នុងភូមិ និងពូជដំណាំជាចំណីប្រូតេអ៊ីន ឬប្លាស្ទិកសម្រាប់ផលិតចកបាយទា ក្នុងករណីលក្ខខណ្ឌអំណោយផល និងវ៉ាក់សាំង ប៉ុន្តែកសិករត្រូវមានមេមាន់ សំភារៈសម្រាប់ធ្វើទ្រុង របងបាំង និងជី ។

ឧបករណ៍/សំភារៈ :

សំភារៈដែលមិនមាននៅក្នុងភូមិ ឬមិនអាចផលិតបានដោយកសិករ អាចត្រូវផ្តល់ឱ្យជាការលើក ទឹកចិត្តដើម្បីចូលរួម និងចែករំលែកបទពិសោធន៍ដល់អ្នកដទៃ ។ សំភារៈ និងឧបករណ៍ត្រូវការសម្រាប់អនុវត្ត 'TIP' នេះមាន :

សំភារៈឧបត្ថម្ភដល់កសិករ

- វ៉ាក់សាំងសម្រាប់កូនមាន់ (ដង្កោរ និងអុតមាន់) សម្រាប់ការ ធ្វើវ៉ាក់សាំងដំបូងប៉ុណ្ណោះ ។
- កំរាលប្លាស្ទិកប្រសិនបើកសិករត្រូវការផលិតចកបាយទា ។
- ចំណីប្រូតេអ៊ីនដែលកសិករមិនអាចផលិតបានដោយខ្លួនឯង (ផ្តល់លើកដំបូងជាការលើកទឹកចិត្ត) ។
- គ្រាប់ពូជដំណាំចំណីសត្វរួមបញ្ចូលទាំងជន្លេន ប្រសិនបើ មានតម្រូវការ ។

ចំណាំ :

- ក្នុងការអនុវត្តន៍ 'TIP' នេះ ដែលមានកសិករច្រើន ចាប់អារម្មណ៍នោះ ចំណាយផ្សេងៗត្រូវចេញដោយកសិករ រួមទាំងតម្លៃសេវាកម្ម ក្រោយពីការធ្វើបង្ហាញម្តង ។
- ភ្នាក់ងារ ផ្សព្វផ្សាយនៅពេលនោះ អាចធ្វើការជាមួយភ្នាក់ងារពេទ្យសត្វភូមិ ប្រសិនបើមានដើម្បីជួយសំរួលដល់ការអនុវត្តន៍ 'TIP' នេះ ។
- ជាទូទៅ កសិករមិនមានប្រាក់សម្រាប់បង់ដល់សេវាកម្ម របស់ភ្នាក់ងារផ្សព្វផ្សាយ ក៏ដូចជាពេទ្យសត្វភូមិដែរ ដូច្នេះភាគី ទាំងសងខាងត្រូវរៀបចំជាកិច្ចព្រមព្រៀង ដោយយកថ្លៃ សេវាកម្ម+ថ្លៃវ៉ាក់សាំងពី១០-១៥ភាគរយ លើចំនួនមាន់ផលិតបាន ។ ធ្វើតាមវិធីនេះ អាចលើកទឹកចិត្តទាំងកសិករ ភ្នាក់ងារផ្សព្វផ្សាយ និងពេទ្យសត្វភូមិ អនុវត្តឱ្យល្អដើម្បី ចែកចាយផលប្រយោជន៍គ្នា ។

ការចូលរួមចំណែកពីកសិករ :

- រៀបចំដីមួយផ្នែកសម្រាប់អនុវត្ត 'TIP' នេះ ។
- មានមេមាន់ ៥ក្បាល សម្រាប់អនុវត្ត 'TIP' នេះ ។
- សំភារៈសម្រាប់សាងសង់ទ្រុង អង្រុតក្រុង និងរបងបិទបាំង ។

- សមាជិកគ្រួសារម្នាក់ទទួលខុសត្រូវលើការងារនេះ រួមបញ្ចូលទាំងការចូលរួមនៅក្នុងកិច្ចប្រជុំ និងពិភាក្សាគ្នានានា ។
- ចំណីមាន់ មាន ចុងអង្ករ និងកន្ទក់ដើម្បីផ្សំចំណីតាមរូបមន្ត ខាងលើ ។

<u>ការពិនិត្យតាមដាន និងវាយតម្លៃ</u> :

ដោយរយៈពេលសម្រាប់កូនមាន់ដែលបានលើកឡើងនៅក្នុង 'TIP' នេះ ខ្លី ភ្នាក់ងារផ្សព្វផ្សាយ ត្រូវចុះជួបកសិករដល់ទីកន្លែង ៣-៩ថ្ងៃម្តង ។ តួនាទី អ្នកផ្សព្វផ្សាយដែលត្រូវធ្វើមានដូចខាងក្រោម :

- រៀបចំការប្រជុំជាមួយកសិករ និងដៃគូរបស់ពួកគេ ដើម្បីពិភាក្សាលើដំណើរការបង្ហាញអាស្រ័យទៅតាមជម្រើសបច្ចេកទេសដែលកសិករបានជ្រើស ។
- ត្រួតពិនិត្យតាមដាននៅតាមផ្ទះនិមួយៗដើម្បីវាយតម្លៃទៅលើការអនុវត្តន៍ 'TIP' នេះ ។
- ថ្លឹងកូនមាន់ជាក្រុមរៀងរាល់ ៥-៧ថ្ងៃម្តងជាមួយម្ចាស់ ។
- រៀបចំការត្រួតពិនិត្យតាមដាន និងវាយតម្លៃដោយមានការ ចូលរួមពីកសិករនៅពេលកូនមានអាយុ ៤០-៤៥ថ្ងៃ ។ នៅថ្ងៃជាមួយគ្នានេះ ភ្នាក់ងារផ្សព្វផ្សាយអាចអញ្ជើញកសិករ ផ្សេងៗទៀតឱ្យចូលរួមវាយតម្លៃ 'TIP' នេះ និងទន្ទឹមគ្នានោះរៀបចំទិវាស្រែកសិករដែលអនុញ្ញាតឱ្យកសិករបង្គោល ចែករំលែកបទពិសោធន៍ដល់អ្នកដទៃ ។

<u>ផែនការ</u> :

ចំពោះ 'TIP' នេះ មិនមានពេលវេលា/រដូវជាក់លាក់ចាំបាច់នោះទេ តែជាការប្រសើរគួរតែចាប់អនុវត្តក្រោយភ្លៀងធ្លាក់ជោគជាំនៅដើមរដូវវស្សា (ជម្ងឺដង្កោរអាចផ្ទុះឡើងនៅពេលភ្លៀងតិចៗដំបូង) ហើយតំបន់លិចទឹកនៅរដូវវស្សា គួរចាប់ផ្តើមក្រោយទឹកសំរក (វិច្ឆិកា-ធ្នូ) ។

## ៣.២ ថវិកាសម្រាប់ការធ្វើបង្ហាញ

ថវិកាសម្រាប់កម្មវិធីផ្សព្វផ្សាយ នឹងប្រែប្រួលអាស្រ័យលើតម្រូវការជាក់ស្តែងនៃសាម៉ីអង្គភាព ។ តារាងថវិកា ខាងក្រោមបានបង្កើតឡើងក្នុងឆ្នាំ ២០០៦ ដោយយោងទៅលើការប៉ាន់ស្មាន លើបទដ្ឋានអនុវត្តបច្ចេកវិទ្យា របស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

| **ថវិកា និង ការសន្មត់** | ចំនួន / តម្លៃ |
|---|---|
| ក្រុមកសិករ (ក) | ៣០ នាក់ |
| ទុនសម្រាប់ទីតាំងធ្វើបង្ហាញ (ខ) | $៨០ |
| ការបណ្តុះបណ្តាលក្រុមកសិករ (គ)<br>- ឯកសារ / ការណែនាំពីបច្ចេកវិទ្យា TIP | $៣០ |
| ការបណ្តុះបណ្តាលក្រុមកសិករ (ឃ)<br>- អាហារសំរន់ | $៩០ |
| ទុនចូលរួមពីកសិករគំរូ (ង) | កំលាំងពលកម្ម<br>មេមាន់ / កូនមាន់<br>ពេទ្យសត្វភូមិ |
| ទិវាស្រែ — អាហារសំរន់ (ច) | $២៥ |
| ទិវាស្រែ — សំភារៈ (ឆ) | $១០ |
| មន្ត្រីកសិកម្មស្រុក-ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ (ជ)<br>- ការបណ្តុះបណ្តាល, ការត្រួតពិនិត្យទីកន្លែងធ្វើបង្ហាញ | $៤២ |
| មន្ត្រីកសិកម្មស្រុក-ប្រាក់ឧបត្ថម្ភ ថ្លៃធ្វើដំណើរ (ឈ) | $២៤ |
| ការចុះត្រួតពិនិត្យ-តាមដាននៅមូលដ្ឋានដោយអ្នកឯកទេស (ញ) | $២០ |
| សរុប | **$៣២១** |

**ការសន្មត់ប្រើប្រាស់មាន:**

ក. ក្នុង បអប មួយ មានក្រុមកសិករ (៣០ នាក់) និងកសិករគំរូដែលមានទីកន្លែងបង្ហាញ ២ កន្លែង

ខ. ទុនសម្រាប់ខួប ៤៥ថ្ងៃ រួមមាន ៥ដុល្លា សម្រាប់ស៊ុមក្រុងមាន់ សំណាញ់២០ដុល្លា ចំណី១៥ដុល្លា=៤០ដុល្លា ទុនសម្រាប់ពីរកន្លែងនេះ = ៨០ ដុល្លា

គ. ឯកសារបណ្ដុះបណ្ដាលបច្ចេកវិទ្យាមានរួមបញ្ចូលទាំងសំភារៈសម្រាប់បង្រៀន មេរៀន ការបញ្ចាំងស្លាយ និង ផ្ទាំងរូបភាពធំៗ ដែលជាដំណើរការនៃវិធីសាស្រ្តបង្រៀន ។

ឃ. ការបណ្ដុះបណ្ដាលក្រុមកសិករមាន ៣វគ្គ មួយវគ្គ មានរយៈពេលមួយថ្ងៃ លើកលែងតែវគ្គ ការធ្វើជីកំប៉ុស្តិ៍ មានតែ ២វគ្គទេ និង ការកំណត់ចំណាត់ថ្នាក់ជី មានមួយវគ្គដែរ

ង. ទុនចូលរួមពីកសិករឬទីកន្លែងបង្ហាញ មួយវដ្ដ មានមេមាន់៥ និងមាន់ឈ្មោល១ និងកូនមាន់រស់៤០-សួនដំណាំសំរាប់ចំណីមាន់ កំលាំងពលកម្ម និង ថវិកាសម្រាប់ពេទ្យសត្វភូមិ

ច. ទិវាស្រែមានកន្លះថ្ងៃ មានតែម្ដងក្នុងវគ្គណាមួយក្នុងចំណោមទាំងបីវគ្គ និងអាចមានការចូលរួមពីកសិករនៅក្បែរៗភូមិប្រហែល ៤០-៦០នាក់

ឆ. សំភារៈសម្រាប់ទិវាស្រែរួមមាន ឧឃោសនស័ព្ទ(មេក្រូ) តង់ និងផ្ទាំងបដារូបភាពផ្សេងៗ ទៀត

ជ. សម្រាប់មន្រ្តីកសិកម្មស្រុក ថវិកាឧបត្ថម្ភរួមមាន៨ថ្ងៃ សម្រាប់ការជ្រើសរើសទីកន្លែងបង្ហាញ /ការចាប់ផ្ដើម / ការត្រួតពិនិត្យតាមដាន ។ ចំពោះការបណ្ដុះបណ្ដាលសម្រាប់ ៣វគ្គ ផ្ដល់អោយ ៦ ថ្ងៃ និងទិវាស្រែផ្ដល់ អោយ២ថ្ងៃ

ឈ. ប្រាក់ឧបត្ថម្ភសម្រាប់ម៉ូតូ ២ដុល្លាសម្រាប់មួយថ្ងៃ ទាំងអស់ ១២ថ្ងៃ

ញ. មន្ទីរកសិកម្មខេត្ត-អ្នកឯកទេសផ្ដល់ជំនួយបច្ចេកទេស និងត្រួតពិនិត្យ-តាមដានការបណ្ដុះបណ្ដាល TIP

## ៣.៣ កន្លែងរកឯកសារបន្ថែម

មជ្ឈមណ្ឌលអភិវឌ្ឍន៍ការចិញ្ចឹមសត្វ និងកសិកម្ម "សែលអាគ្រិត" និងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ។

## ៣.៤ យែនឌ័រ

ស្រ្តីសមរម្យសម្រាប់ជ្រើសរើសក្នុងការចូលរួមនៅក្នុង 'TIP' នេះណាស់ ដោយសារជា ទូទៅពួកគេច្រើនធ្វើការងារនៅក្បែរផ្ទះ។'TIP'នេះអាចជួយស្រ្តីឱ្យបង្កើនចំណូល ដើម្បីគាំទ្រដល់គ្រួសារគេជាពិសេសសម្រាប់បង្កើនអាហាររូបត្ថម្ភដល់កុមារ និងទិញសំភារៈសម្រាប់កូនទៅសាលារៀន ។

ដោយសារអ្នកចូលរួមអនុវត្ត 'TIP' នេះ ភាគច្រើនជាស្ត្រី ការផ្ដល់អទិភាពដល់អ្នកផ្សព្វផ្សាយជាស្ត្រី ក្នុងការរៀបចំការងារនេះនៅតាមភូមិ មានសារៈសំខាន់ណាស់ ។

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង:**

នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ២០០ វិថីព្រះនរោត្តម ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : ០១២ ៨៣៣ ៧៧៧ ឬ ០១២ ៨២៦ ៦១៧

ទូរសារ : ៨៥៥ ២៣ ២១០ ៩៤៨ ឬ ៨៥៥ ២៣ ២១៣ ០១១

អ៊ីម៉ែល : kunso@camnet.com.kh ឬ mak_soeun@camnet.com.kh